ជាប្ដីប្រពន្ធ (ការកូន, ការទៅ) ។

– **ភារណី** ជានាម ប្រែថា ហេតុ, ដំណើរ (សេចក្ដីពយការណ៍) ។

– **ភា** ជានាម ប្រែថា បំពង់សម្រាប់ដាក់ទឹក (កាទឹក) ។

– **ភា់** ជាកិ. គឺសរសេរអសយដ្ឋាន ឈ្មោះអ្នកដែលនឹងទទួលសំបុត្រនៅលើស្រោមសំបុត្រ (កាខ្ទង់សំបុត្រ) ។

៣– ភព :

– **ភព** ជានាម. ប្រែថា សេចក្ដីចំរើន, ដំណើរ, កើត (នៅក្នុងភពនេះ) ។

– **ភប់** ជាកិ. ប្រែថា ជួប, ប្រទះ, ប្រសព្វ (កប់-ប្រសព្វ) ។

x

x x

## ទី៨.- សិលាប្រាសាទ និង ខ្មែរបុរាណ

ប្រទេសកម្ពុជា ជាប្រទេសកុះករបរិបូណ៌ដោយសិលាប្រាសាទ ដែលជាកេរ្តិ៍ដំណែលនៃពួកបុព្វបុរសរបស់ខេមរជនពីក្នុងបុរាណសម័យ ។ ប្រាសាទថ្មដែលមានលម្អដ៏បវរស័ក្តិសមឥតមានពីរនោះ គឺប្រាសាទនគរវត្តដែលសព្វថ្ងៃហៅក្លាយជាអង្គរវត្ត ។ សិលាប្រាសាទនេះមានក្បូរក្បាច់រចនាដ៏បណ្តាច់អស្ចារ្យ កុំថាតែមនុស្ស ទោះទាំងទេវតា ក៏គង់និយមការសរសើរពុំខាន ។

តាមពាក្យបរម្បរាថា ព្រះពិស្ណុការមកជួយសាង តែបើតាមសិលាចារឹកជាក់ស្តែងថា ជាការស្នាដៃនៃពួកពលរដ្ឋក្រីជាមនុស្សជាតិខ្មែរសុទ្ធ ជាពួកកុលបុត្រ តក្កវិទ ចេះពិនិត្យកិច្ចការ ជាអ្នកបរិបូណ៌ដោយសិល្បវិទ្យាសាស្ត្រ សាងក្នុងរាជ្យព្រះកេតុមាលាក្សត្រាធិរាជខេមរជាតិ ។

ខេមរជនសម័យបុរាណ ជាអ្នកមានអធ្យាស្រ័យគម្ពីរភាព

ពេញចិត្តនឹងការសិក្សាបំណេះវិជ្ជាទាំងផ្លូវលោក ទាំងផ្លូវធម៌ ហើយឧស្សាហ៍ស្រាវស្រទេញ រៀនទន្ទេញដោយការម៉ឺងម៉ាត់ ប្រយ័ត្នក្រែងសាបសូន្យការចេះដឹង ព្រោះហេតុហ្នឹងហើយបាន ជាខេមរជនបុព្វបុរសរបស់យើងធ្វើសិលាប្រាសាទថ្មកៗអនេក អន័ក្សអស្ចារ ស្ទើរតែនឹងគណនារាប់ឲ្យសព្វគ្រប់ពុំបាន ។

ជាតិខ្មែរក្នុងជំនាន់បុរាណ មិនមែនចេះត្រឹមតែការហត្ថកម្មប៉ុណ្ណោះទេ សូម្បីតក្កវិជ្ជា និងវិទ្យាអក្សរសាស្ត្រ ព្រមទាំងសិល្បករ ក្បួនច្បាប់ ក្រិត្យក្រម តូរ្យតន្ត្រី ក៏មានល្បីថាចេះគ្រប់មុខ ទុកបែបបទជាភស្តុតាងឲ្យយើងឃើញប្រាកដនូវសិលាចារឹកដ៏វិចិត្រ មានតែងគាថាជាពាក្យកាព្យឆន្ទសំស្ក្រឹត ដោយពិនិត្យពិច័យ ជាសម្នាដៃនៃបណ្ឌិតកវីអ្នកប្រពន្ធ មានលក្ខណៈត្រឹមត្រូវគ្រប់គ្រាន់ ឥតមានវិបត្តិល្អៀងឡៀងឃ្លាតខាតខុសឡើយ ។

## សំណួរ

**១– ចូរពន្យល់ពាក្យ** ទាំងឡាយនេះ : តក្កវិទ,

គម្ពីរកាព, ស្រវាស្រទេញ, ក្រិត្យក្រម, ត្យូ

តន្ត្រី, សំស្ក្រឹត ។

**២– ចូរអ្នកសម្ពន្ធប្រយោគ** : "ខេមរជនសម័យ

បុរាណ ៗលៗ គណនាត្រាប់ឲ្យសព្វគ្រប់

ពុំបាន" ។

**៣– មានអ្នកខ្លះពោលថា** ខ្មែរមិនអាចកសាង

ប្រាសាទថ្មីឲ្យមានលម្អយ៉ាងនេះទេ គឺច្បាស់

ជាព្រះពិស្ណុការមកជួយសាង, ខ្លះទៀតឆ្លើយ

ថា : គ្មានពួកទេពតាណាជួយសាងទេ គឺ

ប្រាកដជាស្នាដៃ នៃពួកបុព្វបុរសខេមរជាតិ

យើង ។ តើអ្នកយល់ដូចម្តេចចំពោះមតិ

ទាំងពីរខាងលើនេះ ? ។

មធ្យមសិក្សាប័ត្រ

( លើកទី ២ ថ្ងៃ ២៦-៦-៦១ )

## កំណត់ចំណាំ

១. អក្ខរាវិរុទ្ធ.–

– សិលា (ន) ថ្ម (កុំច្រឡំនឹងពាក្យ សីល ឬ សីលា ចារ, សីលា ធុស្សុត) ។

– លម្អ (សរសេរតម្រួត ព្រោះមកពីពាក្យ ល្អ ៗ ពីមុនសរសេរ លំអ ដូច្នេះ) ។

– ទេពតា (អាចសរសេរ ទេវ្តា បាន) ។

– ភ័ស្តុតាង (អានថា ភ័ស្ត – តាង; – សរសេរ ភ័ស្តុ - តាង) ។

– ប្រយ័ត្ន (យ័ត្ន សរសេរ យ័ និង ត្ន) ។

– សម្នាដៃ (សរសេរតម្រួត ព្រោះមកពីពាក្យ ស្នា ៗ ពីមុនសរសេរ សំណាដៃ) ។

– អង្គាស (អាចសរសេរ អង្ឃាស បាន) ។

២. ន័យរបស់ពាក្យ.–

– បវរសក្តិ (ស.ន.) រុងរឿង ប្រសើរសក្តិសម ។

– **ពាក្យបរម្បរា** (ស.ន.) ពាក្យមិនពិត, ពាក្យនិយាយតៗគ្នាពីមាត់មួយទៅមាត់មួយទៀត ។

– **ព្រះពិស្ណុការ** (ន) មកពីពាក្យ វិស្សកម្ម ដែលជានាមនៃទេវតា អ្នកមានបំណេះខាងការជាង ជាអ្នកសម្រេចកិច្ចការថ្វាយព្រះឥន្ទ្រ ។

– **វឌ្ឍកី** (ន) ជាងឈើ (វឌ្ឍកីកម្ម=ការជាងឈើ)។

– **តក្កវិទូ** (ន) អ្នកចេះតក្កវិជ្ជា គឺចេះវិជ្ជាត្រិះរិះរកហេតុផលដែលប្លែកឲ្យឃើញប្រាកដ ដោយគំនិតខ្លួនឯង (ដូចគ្នានឹងពាក្យតក្កវិញ្ញូ) ។

– **សិល្ប៍សាស្ត្រ** (ឬសិល្បសាស្ត្រ) (ន) ក្បួនរៀនសិល្បៈ, បំណេះជាង ។

– **គម្ភីរភាព** (ស.ន.) ភាពជ្រៅ, ជម្រៅ ។

– **ស្រវាស្រទេញ** (កិ.) ខិតខំ សង្វាតពេញកម្លាំង, ខ្មីឃ្មាត ។

– **ក្រឹត្យក្រម** (ស.ន.) (ក្រឹត្យ = ច្បាប់ដែល

តែងតាំងឲ្យអនុវត្ត = le kret, le décret ;

**ក្រម** = ច្បាប់ដែលរដ្ឋសភាអនុមតិ ហើយ

ចុះព្រះហស្តលេខានៃព្រះប្រមុខរដ្ឋសំរាប់អនុវត្ត

ជាទូទៅ = la loi ) – ក្រិត្យក្រម = លំដាប់

នៃកិច្ច ។

– **តូរ្យតន្ត្រី** (ន.) គ្រឿងភ្លេងដេញដំ ផ្លុំ កូត ។

– **គាថា** (ន.) កម្រងវាចាដែលមានរបៀបកំណត់

ដោយខ្សល់អក្សរមាន ឆន្ទ គណៈ ឃ្លា ល្បះ ។

– **សំស្ក្រឹត** (ន.) ឈ្មោះភាសាដើមដំបូងបំផុតរបស់

ពួកហិណ្ឌូ ។

៣- **សធិសសព្ទ** នៃពាក្យ :

១- សីល.–

– **សីល** (ន ) ការកាន់ ឬ ប្រព្រឹត្តល្អដោយកាយវាចា

(សីលកថា, សីលគុណ) ។

– **សិល្ប** (ន.) សរសេរបានជា សិល្បៈ ឬសិល្ប៍

(រៀនសិល្ប៍, សិល្បវិជ្ជា) ។

២– ចិត្ត.–

– **ចិត្ត** (ន) (ចិត្តត្រង់, ចិត្តល្អ) ។

– **ចិត្ត** ឬ ចិត្រ (គ. ឬ ន.) ដែលគេវិចិត្តហើយ, ដែលគេធ្វើដោយផ្ចិតផ្ចង់ (វិចិត្រ, ចិត្រករ, ចិត្តវិជ្ជា ឬចិត្រវិទ្យា) ។

– **ចិត** (កិ.) កាត់ជាចំណិត (ចិតបន្លែ) ។

– **ចិតសិប** (ប. សំ) ចំនួនដប់ ៧ ដង ។

x

x x

## ទី៩.– ការហត្ថកម្មនៅវាលសោះខ្យល់

ដើម្បីឲ្យប្រជារាស្ត្រប្រកបដោយសុខុមាភាព ឧត្តុង្គឧត្តម សមតាមសម័យបច្ចុប្បន្ន ព្រះបិតាឯករាជ្យជាតិ ជាព្រះអគ្គមគ្គុទ្ទេសក៍នៃយើង ព្រមទាំងរាជរដ្ឋាភិបាល បានពិនិត្យពិច័យរៀបចំឲ្យអនុវត្តនូវផែនការប្រាំឆ្នាំដោយមធ្យ័ត ។

មិនមែនគ្រាន់តែព្រះអង្គទ្រង់ចំណាយកាយពលផ្ទាល់ព្រះអង្គដើម្បីទ្រង់បំពេញការហត្ថកម្មប៉ុណ្ណោះទេ ព្រះបិតានៃយើងទ្រង់ត្រាស់បង្គាប់ឲ្យមន្ត្រីគ្រប់ជាន់ថ្នាក់ អ្នកស្រុក កងយោធពលខេមរភូមិន្ទ យុវជន យុវតី ឲ្យចូលរួមធ្វើការជួនបណ្តារាស្ត្រគ្រប់ទុគ៌ម ជនបទ គ្រប់ភូមិ ស្រុក និងខេត្តនៃព្រះរាជអាណាចក្រ ។

នៅការដ្ឋាននៃវាលសោះខ្យល់ ជារៀងរាល់ថ្ងៃ វេលាព្រឹកព្រាងស្វាងអរុណោទ័យ សូរស័ព្ទត្រែបានបន្លឺឡើងខ្ទរខ្ទារទាំងព្រៃព្រឹក្សា កម្មករថ្មីប្រញាប់ប្រញាល់កាន់ចបបង្គីគ្រប់ ៗ ដៃ ហើយចរចេញទៅបន្តកិច្ចការរបស់ខ្លួន ។ គេកាប់គាស់ដី ក្រោមសូរ្យសែង ក្រោមភ្លៀង ផ្គរ ឬក្រោមផ្លេកបន្ទោរ ព្យុះព្យាមាក៏ពិតមែន ប៉ុន្តែគេសោមនស្ស សប្បាយរីករាយ ខំពុះពារកាប់ឆ្ការឧបសគ្គនានា យកជ័យជំនះលើធម្មជាតិសម្រាប់ជាប្រយោជន៍ជូនប្រទេសជាតិ ។

ព្រោះហេតុហ្នឹងហើយ បានជានៅពេលធ្វើការ គេឮ

សូរសព្ទសំណើចអឹងអាប់ផុសចេញពីការសន្ទនាគ្នា ជាការកំដរនិងលំហែបរិយាកាសជានិរន្តរ៍ ៗ ប៉ុន្តែមិនយូរប៉ុន្មានឡើយ លទ្ធផល គឺផ្លែផ្កានៃការប្រឹងប្រែងនៃកម្មវិធីថ្មីពីគ្រប់មជ្ឈដ្ឋានក៏បានលេចជារូបរាងឡើង ៗ

ទំនប់ទឹកនៅកល់សោះខ្យល់មានសណ្ឋានធំ បានលាតលូនសន្ធឹងរូបស្តុកស្តឹងយ៉ាងប្រត្យក្សចំពោះមុខយើងពល់គ្នា ៗ ពេលនោះសម្តេចទ្រង់យាងទៅធ្វើបុណ្យសម្ពោធយ៉ាងអធិកអធម មានប្រជារាស្ត្រកុះករឈូឆរ ចូលមកអបអរសាទរក្រាបប្រណិប័តន៍សំដែងស្វាមីភក្តិចំពោះព្រះអង្គ ៗ

ក្នុងសុន្ទរកថាមួយយ៉ាងវែង ព្រះអង្គបានបញ្ជាក់ប្រាប់កូនចៅថា “ការសាមគ្គីគ្នាជាធុងមួយ អាចផ្តល់នូវអត្ថប្រយោជន៍នូវវឌ្ឍនភាពនិងជោគជ័យជូនជាតិ ដូចមានទំនប់ទឹកនេះជាភស្តុតាងស្រាប់” ៗ

## សំនួរ

**១– ចូរពន្យល់ពាក្យ** សុខុមាលភាព, អរុណោ-

ន័យ, អធិកអធម, វិវឌ្ឍនភាព ។

២- **ចូរបង្ហាញន័យ** នៃពាក្យ "មហា" និង ពាក្យ "ឧត្តម" តើខុសគ្នាយ៉ាងណា ? ឧទាហរណ៍ ។

៣- **តាមគំនិត** នៃការសរសេរតាមសូត្រនេះ តើការហត្ថកម្មមានតម្លៃយ៉ាងណាខ្លះ ?

**កំណត់បំណាំ**

១- **អក្ខរាវិរុទ្ធ** .–

– **ហត្ថកម្ម** (ហត្ថ សរសេរ ត ជើង ថ ។ កុំច្រឡំ ហត្ថ និង ហស្ត ។ ចុះហត្ថលេខា, ត្រង់ឡាយព្រះហស្តលេខា) ។

– **ព្រះបិតាឯក្សរាជ្យ** ឯករាជ្យ ជានាម ។ ប្រទេសឯករាជ = រាជ ជាគុណនាម) ។

– **មគ្គុទ្ទេសក៏** (អាចសរសេរជា មគ្គុទេសក៍ ដូចេះបាន) ។

- ពិច័យ (សរសេរ ច័ និង យ ។ គ្មានជើង ( ្ញ ) ទេ) ។
- មធ្យ័ត (សរសេរ ម-ធ្យ័ និង ត) ។
- ទុគ៌ម (អាចសរសេរ ទុរគម ដូច្នេះបាន) ។
- ខែត្រ (អាចសរសេរ ខេត្ត ដូច្នេះបាន) ។
- ព្រឹកព្រាង (ព្រាង ខុសពី ព្រៀង លាន) ។
- សួរស័ព្ទ (ស័ព្ទ អាចសរសេរ សព្ទ ដូច្នេះបាន) ។
- ខួរខ្វារ (សរសេរ រ ខាងចុងដូចគ្នាទាំងពីរពាក្យ) ។
- សោមនស្ស (សរសេរ ស ជើង ្ស) ។
- ទ្វារ (មាន រ ខាងចុង) ។
- ធម្មជាតិ (សរសេរ ធម្មជាត ដូច្នេះបាន) ។
- សម្រាប់ (សរសេរតម្រូត ពីព្រោះមកពី ស្រាប់ ពីមុនសរសេរ សំរាប់) ។
- កំដរ (សរសេរ រ ចុង ។ ពីមុនសរសេរ កម្ដរ ដូច្នេះបាន តែឥឡូវឈប់សរសេរយ៉ាងនេះហើយ) ។

– **លំហែ** (អាចសរសេរ រំហែ ដូច្នេះបាន ។ គ្មាន រ ចុងទេ) ។

– **និរន្តរ៍** (សរសេរ និរន្តរ ដូច្នេះបាន) ។

– **លទ្ធផល** (លទ្ធ សរសេរគ្មាន ( ់ ) ទេ) ។

– **សម្ពោធ** ជា កិ. (ប្រើជានាម សរសេរ សម្ពោធ ឬ សម្ពោធន៍ ។ ដូចកាលគេសរសេរ សម្ភោជ ឬ សម្ភោឡ ដូច្នេះក៏មាន) ។

– **អធិករអធម** (អានថា អៈធិក-អៈធំ) ។

– **កុះករ, ឈូឆរ, អបអរ, សាទរ** (ករ, ឆរ, អរ, ទរ សរសេរ រ ចុង) ។

– **ប្រណិប័តន៍** (សរសេរ ប័ – ត និង ន៍) ។

– **ស្វាមីភ័ក្តិ** (អាចសរសេរ ភក្តិ ដូច្នេះបាន) ។

២- ពន្យល់ពាក្យ :

– **សុខុមាលភាព** ភាពនៃបុគ្គលអ្នកមានសេចក្ដី

សុខ, ការដែលធ្លាប់តែស្រណុក ។

- **អរុណោទ័យ** (មកពី សំ. បា. អរុណ + ឧទយ ប្រែថា "ការរះឡើង" ការរះឡើងនៃអរុណ, គឺពេលអរុណរះ, វេលាថ្ងៃរះ ។

- **អធិកអធម** (មកពីសំ. បា. អធិក = ក្រៃលែង, លើសលែង, លើសលប់, រុងរឿង, ហ៊ុកហ៊ាក់ + អធម = ថយថោក, ថោកទាប, មិនរុងរឿង, រមែះរមោះ, កយេរង៏, បន្ទាប់បន្ទន់) = ខ្មែរប្រើពាក្យនេះចំពោះតែពិធីបុណ្យ ដែលរុងរឿងផង រមែះរមោះ រប៉ុចរប៉ុកយរង៏ខ្វះផង ។

- **វិជ្ជនភាព** (បា. វិជ្ជន: = សេចក្តីចំរើន + ភាវ: = ភាព) ភាពចំរើន ល្អតណាស់ ។

៣- **សទិសសព្ទ** នៃពាក្យ :

១- អប :

- **អប** ជា ន. ជាបុព្វបទសម្រាប់រៀងភ្ជាប់ពី

ខាងដើមសព្ទដទៃ មានសេចក្ដីថា "ប្រាស ចាក, ឃ្លាតចាក, ឃ្លាងចាក, ឆ្ងាយ, ទៅឆ្ងាយ, គ្រឡប់, ត្រឡប់ជា, បែរជា, ផុត, រួចផុត, មិន, ឥត (អបករណ៍, អបច័យ, អបទេស, អបទ្រព្យ, អបធន, អបមង្គល ឬ អពមង្គល, អប-លក្ខណ៍) ។

– **អប្ប** ជា គុ. ប្រែថា តិច, តួច, ស្ដួចស្ដើង (អប្បទ្រព្យ, អប្បធន, អប្បបញ្ញា ឬ អប្បប្រាជ្ញា)

– **អាប់** ជា កិ. ប្រែថា ផាត់ប្រាក់កាក់ ឬលុយ ឲ្យទៅអ្នកវិញ (គេអាប់លុយឲ្យខ្ញុំលើស) ។

– **អាប់** ជា គុ. ប្រែថា ដែលអន់ ឬតិចពន្លឺ, ថយ លំអ, ថោក, ទន់ទាប, ខ្សោយ, តិច (អាប់គំនិត, អាប់ជាតិ, អាប់មុខ, អាប់អួ, អាប់គួន ឬអាប់ឱន) ។

– **អព្ភ** ឬ **អព៌្ភ** ជានាម គឺពពកខាប់ ឬ ពពក

ក្រាស់ (មេឃចុះអ័ព្ទ) ។

២- កាំ :

- **កាំ** ជានាម ប្រែថា ថ្នាក់, ផាន់ (កាំជណ្ដើរ, កាំរទេះ)

- **កម្ម** ជានាម ប្រែថា អំពើ (រងកម្ម, កម្មករ) ។

x

x x

| ទី១០.— . . . . . . . . (១) |
|---|

នៅរាជធានីភ្នំពេញ មហាជនប្រុសស្រី ក្មេងចាស់និងពួកអ្នកទេសចរបរទេស បាននាំគ្នាទៅមើលព្រះរាជពិធីអុំទូកលយប្រទីបផ្ដាលា និងសំពះព្រះខែ ដែលបានរៀបចំធ្វើឡើងយ៉ាងអឹកធឹកជាងពីឆ្នាំមុន ៗ ។ កីឡាប្រណាំងទូកនេះ ជាកីឡាមួយដ៏ធំអស្ចារ្យនៅប្រទេសកម្ពុជា មិនឲ្យបាត់បង់ទៅណា

---

(១) អត្ថដើមគ្មានឈ្មោះទេ ។ សៀវភៅសហជីវិន ជឹម-ទៅ ឈ្មោះសរសេរតាមសូត្រឪប្ដូម ចេញឆ្នាំ ១៩៦៣ បានពិគ្រោះនិងខ្ញុំដាក់បំណងជើងថា "ព្រះរាជពិធីអុំទូកលយប្រទីប" ។

សាធារណរដ្ឋប្រជាមានិតកម្ពុជា
បណ្ណាល័យជាតិ
លេខបញ្ជី :

បានរក្សាទុកចំនួនច្រើនសតវត្សមកហើយ ។

នៅក្នុងសួនច្បារដ៏វិចិត្រដោយទីធ្លាយ៉ាងល្អស្អាត និង ដោយរុក្ខជាតិពណ៌ផ្សេងៗ នៅលើផ្ទៃនៃស្មៅយ៉ាងខៀវខ្ចី បញ្ចាំងដោយពន្លឺអគ្គិសនីដ៏ភ្លឺថ្លា មហាជនប្រុសស្រីតុបតែងខ្លួនយ៉ាងល្អគ្រប់ៗគ្នា ឈរនិងដើររេកមៀងមើលប្រទីបនិងកាំជ្រួចដែលកំពុងតែសំដែងនូវលម្អពួដ៏កណ្ដាលមហាគង្គានិងពួដ៏កណ្ដាលអាកាសវេហាស៍ ហាក់បីដូចជាពួកទេវតានាំគ្នាដើរលេងក្នុងសួនទេវលោក ។

ដំនោរខែកត្តិក ក៏បានបក់មកអំពីទិសខាងជើងយ៉ាងរំភើយៗ កម្ចាត់អស់ទាំងសេចក្ដីស្អុះស្អាប់ បង្ហួតអស់ទាំងញើស ហើយបបោសអង្អែលហទយវត្ថុនៃមហាជនឲ្យអស់ នូវសេចក្ដីទុក្ខព្រួយគ្រប់យ៉ាង ដែលមានមកពីថ្ងៃមុន ។

ដល់ពាក់កណ្ដាលអធ្រាត្រ សំឡេងសកវាទនៅព្រះដំណាក់ផែ ក៏បានបន្លឺឡើងដោយបទយ៉ាងសែនពីរោះ ហាក់បីដូចជាទឹកអម្រឹត ដែលទេពតាយកមកស្រោចស្រប់បេះដូងនៃ

មហាជនឲ្យបានរីករាយត្រជាក់ត្រជុំក្សេមក្សាន្ត សម្រួលសម្រាន្តក្នុងអារម្មណ៍ដ៏សែនមនោរម្យឥតឧបមា ។

មហាជនសរសើរស្ងើរតែរាល់មាត់ ដល់រាជរដ្ឋាភិបាលសង្គម ដែលបានខិតខំរៀបចំទីក្រុងភ្នំពេញ ដោយមានវាចាថា រាជធានីយើង បើសម្តេចព្រះបិតាទ្រង់គង់នៅជាព្រះអគ្គមគ្គុទេសក៍ដរាបណា ដរាបនោះនឹងបានទៅជាទីក្រុងមួយយ៉ាងល្អឆើតឆាយ ។

## សំនួរ

១. ចូរពន្យល់ពាក្យ ទេសចរ, ប្រទីបផ្កាលា, ភ្លើងកណ្តាលអាកាស, ហទយរត្ន, ទឹកអម្រឹត, សែនមនោរម, អគ្គមគ្គុទ្ទេសក៍ ។

២– ចូរបង្ហាញន័យនៃពាក្យ "មហា" និងពាក្យ "ឧត្តម" តើខុសគ្នាយ៉ាងណា ? ឧទាហរណ៍ ។

៣- ចូរសម្ពន្ធពាក្យត្រង់ឃ្លា : "មហាជនប្រុស

ស្រីតុបតែងខ្លួនយ៉ាងល្អគ្រប់ៗ គ្នា ឈរនឹង ដើររេក » ។

មធ្យមសិក្សាប័ត្រ
លើកទី ៣ ថ្ងៃ ៩-៧-៦២(១)

## កំណត់បំណាំ

**១- អក្ខរាវិរុទ្ធ.–**

– **ទេសចរ** (ជានាម. គឺជនអ្នកធ្វើដំណើរលំហែកម្សាន្ត) ។ កុំច្រឡំនឹង ទេសបរណ៍ ជានាម ប្រែថា ការធ្វើដំណើរកម្សាន្ត ឬឈ្មោះក្រសួង ។ ក្រសួងទេសបរណ៍ ។

– **អ៊ឹកធឹក** (សរសេរនឹងស្រៈ ឹ ។ ឬអាចសរសេរ អ៊ឹកអធឹក ក៏បាន) ។

– **សតវត្ស** (អាចសរសេរ សតវត្សរ៍ ដូច្នេះបាន)។

---

(១) បានជាមានលើកទី ៣ ពីព្រោះលើកទី ២ ត្រូវផាបោលដោយមានឧបសគ្គមិនល្អ កាលពេលប្រឡងលើកទី ២ នោះ ។

– ប្រទីប (សរសេរទនិងស្រៈ ី និង ប ។

– លម្អ (សរសេរតម្រួត មកពីពាក្យ ល្អ ។ ពីមុន សរសេរ លំអ បាន) ។

– វេហាស៍ (អាចសរសេរ វេហា ដូច្នេះបាន) ។

– ជំនោរ (សរសេរ រ ចុង) ។

– ភត្តិក (សរសេរ ត ជើង ត និងស្រៈ ិ និង ក)។

– ភម្លាត់ (សរសេរតម្រួត មកពីពាក្យ ភ្លាត់ ។ ពីមុនសរសេរ ភំលាត់ បាន) ។

– អធ្រាត្រ (អានថា អធ្រាត ។ សរសេរ ធ្រា និង ត្រ) ។

– សំឡេង (តាម វ. គ. ខ. ភាគទី ២ ថ្មី ទំព័រ ១៤២៨ មិនសរសេរ សម្លេង ដូច្នេះទេ) ។

– សភាវាទី (ភិទ៏ សរសេរ ភិ និង ទ៏) ។

– ពីរោះ (មិនមែនពិរោះទេ) ។

– អម្រឹត (សរសេរនិងស្រៈ ឹ និង ត ។ គេអាច

សរសេរ អម្ពុត ដូច្នេះបាន) ។

- ស្រោចស្រប់ (អាចសរសេរ ស្រោបស្រព ដូច្នេះបាន) ។

- សម្រួលសម្រាន្ត (សរសេរតម្រួត មកពីពាក្យ ស្រួល-ស្រាន្ត ។ ស្រាន្ត សរសេរ ន ជើង ត) ។

- មនោរម (អាចសរសេរ មនោរម្យ ដូច្នេះបាន ។

- មគ្គុទ្ទេសក៍ (អាចសរសេរ មគ្គុទេសក៍ ដូច្នេះ បាន) ។

១- ពន្យល់ពាក្យ

- ទេសចរ (ន) ជនអ្នកធ្វើដំណើរលំហែកម្សាន្ត ។

- ប្រទីបជ្វាលា (ន) ប្រទីបច្រើនដែលដាក់រាយ ជាជួរ ជាសន្លាក់នៅសុីមបុរនៅប្រពាសបញ្ជរ អុជភ្លឺរុងរឿងក្នុងការធ្វើបុណ្យជាដើម ។

– **ព្ជជីកណ្ដាលអាកាស** នៅនាកណ្ដាលអាកាស កណ្ដាលលំហមេឃ ។

– **ហទយវត្ថុ** (ន) លំនៅរបស់ចិត្ត គឺបេះដូង ទឹកចិត្តនេះឯង ។

– **ទឹកអម្រឹត** (ន.) ទឹកទិព្វ ផឹកទៅមិនចេះស្លាប់។

– **សែនមនោរម** ជាទីសប្បាយក្នុងចិត្ត, រីករាយក្រៃលែងក្នុងចិត្ត ។

– **អគ្គមគ្គុទ្ទេសក៍** (ន.) អ្នកដឹកនាំយ៉ាងធំ យ៉ាងសំខាន់ ៗ ក្នុងអត្ថបទនេះ សំដៅចំពោះសម្ដេចព្រះ **នរោត្តម-សីហនុ** ព្រះប្រមុខរដ្ឋ បិតាឯករាជ្យ អព្យាក្រិត្យនិងបូរណភាពនៃប្រទេសកម្ពុជាយើង ។

៣- **សទិសសព្ទ** នៃពាក្យ :

១- ទុក.–

– **ទុក** ជាកិ. ដាក់វត្ថុក្នុងទីណាមួយដើម្បីឲ្យគង់នៅ

(ទុកទ្រព្យ, ទុកដាក់) ។

- **ទុកចិត្ត** (ដាក់. សង្ឃឹម, ជឿជាក់ថា (ខ្ញុំទុកចិត្តលោកហើយ) ។

- **ទុកជា ឬ បើទុកជា** និ. ទោះបី, ទោះជា, សូម្បី, ទោះបីបើ (ការនេះទុកជាជាដ៏ណាក៏ធ្វើមិនកើតដែរ) ។

- **ទុក្ខ** (ន.) សេចក្ដីព្រួយ, សេចក្ដីលំបាក (កើតទុក្ខ, មានទុក្ខសោក) ។

២- សក្តិ .-

- **សក្តិ ឬ ស័ក្តិ** (ន.) អំណាច, កម្លាំង (អ្នកមានស័ក្តិ, ស័ក្តិតូច ធំ) ។

- **សកវាទី** (ន.) (បទសកវាទ) ។

- **សកម្ម** (គុ.) ដែលនៅមិនស្ងៀម (actif) ។

- **ស័ក** (ន.) កាលសម័យ, យុគ (សកពជ) ។

- **សារ៉ាំ** (ន.) យ័ន្ត, អក្សរដែលចាក់នឹងម្ជុលទៅ

ក្នុងសាច់ (គាត់នេះមានសាក់រូបនៅនឹងដៃ) ។

– **សវាក់** (កិ.) ចាក់ដោយម្ជុលបញ្ចូលទឹកខ្មៅក្នុងសាច់ (ចូលចិត្តចង់សាក់ ខ្ញុំសាក់ឲ្យ) ។

x

x x

## ទី១១– ប្រាសាទព្រះវិហារ

ក្នុងចំណោមសិលាប្រាសាទខ្មែរបូរាណទាំងឡាយ ព្រះវិហារជាបូរីយដ្ឋានដ៏វិចិត្រមួយ ដែលថិតយ៉ាងខ្ពស់ត្រដែតលើខ្ពង់ពបស៊ើនៃកំដងវែកក្នុងខេត្តកំពង់ធំ ត្រង់ព្រំប្រទល់នៃប្រទេសកម្ពុជានិងប្រទេសថៃ ។

ប្រាសាទព្រះវិហារនេះ បានកសាងឡើងដំបូងបង្អស់ដោយព្រះបាទយសោវរ្ម័នក្នុងចុងសតវត្សទី ៩ ដើម្បីឧទ្ទិសថ្វាយព្រះសិខរីស្វរៈ ។ លក្ខណៈគ្រប់បែបទាំងអស់នៃប្រាសាទនេះ តាំងពីទម្រង់ផែនការ របៀបសំណង់ ឬក្បូរក្បាច់រចនាផ្សេង ៗ គឺជារបស់សិល្បៈខ្មែរសុទ្ធសាធ សូម្បីនៅ

តាមសិលាចារឹកសោត ក៏គេឃើញតែអក្សរខ្មែរនិងសំស្ក្រឹតប៉ុណ្ណោះ ៗ ភ័ស្តុតាងដ៏ពិស្តារទាំងនេះ បញ្ជាក់យ៉ាងប្រត្យក្សថាព្រះវិហារជារបស់ខ្មែរពិតប្រាកដ ក៏ប៉ុន្តែដោយសារពួកចក្រពត្តិបារាំង ប្រាសាទព្រះវិហារបែរជាធ្លាក់នៅក្រោមការត្រួតត្រារបស់ប្រទេសថៃទៅវិញ តាំងពីសម័យអាណានិគមមកម្ល៉េះរហូតដល់ប្រទេសកម្ពុជាបានឯករាជ្យវិញហើយ ប្រទេសថៃក៏នៅតែពុំព្រមប្រគល់ព្រះវិហារមកឲ្យខ្មែរឡើយ ហើយថែមទាំងប្រើឧបាយមិច្ឆាចារកំលោភបំពានដោយប្រកាន់ថា ប្រាសាទនេះជារបស់ខ្លួនជាដរាប ទើបតែក្នុង ឆ្នាំ ១៩៦២ នេះដោយស្នាព្រះហស្ថដ៏ឆ្នើមនៃសម្តេចឪ ដែលព្រះអង្គខិតខំយ៉ាងពេញព្រះសមត្ថភាព ក្នុងការទាមទារដោយសន្តិវិធីនេះហើយបានជានៅថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ ១៩៦២ ប្រជាពលរដ្ឋខ្មែរទាំងមូលបានទទួលមហាជោគជ័យដ៏សំបើមអស្ចារ្យ ដោយតុលាការអន្តរជាតិបានវិនិច្ឆ័យជាឯកច្ឆន្ទថា ព្រះវិហារជារបស់ខ្មែរ ។

ដំណឹងដ៏សែនរីករាយនេះ ធ្វើឲ្យខ្មែរទាំងអស់ក្រោកឡើងស្រែកជយឃោសអបអរសាទរទទួលព្រះវិហារដែលបានវិលត្រឡប់មកជាសម្បត្តិរបស់ខ្មែរដូចដើមវិញ ហើយដើម្បីបង្ហាញដល់សកលលោកឲ្យស្គាល់ទិនដ៏ធំត្ឋប្បាស់នោះ កាលពីថ្ងៃទី ៥ ខែមករា ឆ្នាំ ១៩៦៣ សម្តេចព្រះប្រមុខរដ្ឋព្រះអង្គទ្រង់យាងទៅធ្វើព្រះទស្សនកិច្ចជាផ្លូវការនៅប្រាសាទព្រះវិហារជានិមិត្តរូបនៃមត៌កខ្មែរ ។

## សំនួរ

១– **ចូរពន្យល់ពាក្យ** ព្រះសិខរិស្វរ:, មច្ឆាបារ, ឯកច្ឆន្ទ។

២– **ពាក្យ « វិហារ »** ត្រូវសរសេរដាក់ត្រីសព្ទដែរឬទេ ? ព្រោះអ្វី ? ចូរអធិប្បាយអំពីលំនាំនៃការអានពាក្យទ្វេព្យាង្គ ។

៣– **ចូរធ្វើសម្ពន្ធពាក្យ** ទាំងឡាយ ក្នុងឃ្លាដូចតទៅ : “ក្នុងចំណោម . . . . វិចិត្រមួយ” ។

មធ្យមសិក្សាបត្រ

លើកទី១ ថ្ងៃ ១ - ៣ - ៦៣

## កំណត់ចំណាំ

១- ពន្យល់ពាក្យ .-

- ព្រះសិខរិស្វរៈ (ន.) (មកពីពាក្យ សិខរ = "កំពូល, បុង" + ឥស្វរៈ = "ឥស្វរ, ដែលធំ, ជាម្ចាស់លើលោក") គឺព្រះឥសូរជាកំពូលលោក ។

- មិច្ឆាចារ (ន.) ការប្រព្រឹត្តនូវអំពើអាក្រក់, មារយាទអាក្រក់ ថយថោក ។

- ឯកច្ឆន្ទ (ន.) ចំណង់តែមួយ, បំណងតែមួយ, បំណងត្រូវគ្នាតែមួយ, ដែលមានបំណងត្រូវគ្នាតែមួយ, ដែលព្រមចិត្តគ្នា ។

២- អក្ខរាវិរុទ្ធ.-

- បូរាណ (អាចសរសេរ បុរាណ ដូច្នេះបាន) ។

- ឋិត (អាចសរសេរ ស្ថិត ដូច្នេះបាន) ។

- ពិស្តារ (សរសេរមាន រ ចុង) ។

– **ឪបរ** (សរសេរមាន រ ជុង) ។

– **អបអរសាទរ** (អរ, ទរ សរសេរ រ ជុង) ។

– **មត៌ក** (សរសេរ មរតក ឬ ម្រឹតក ដូច្នេះបាន) ។

– ៣– **សទិសសព្ទ** នៃពាក្យ :

១– ព្រំ (កុំសរសេរ ព្រុំ)

– **ព្រំ** ជានាម ប្រែថា តារីកដី (ព្រំដែន, ព្រំប្រទល់) ។

– **ព្រំ** ជាកិ. គឺប្រក់ក្តិត ឬ បូកបាយអរក្តិតត្រង់កន្លែងប្រទល់ក្បាលក្បឿង (ព្រំផ្ទះ, ព្រំសាលា) ។

– **ព្រំ** ជានាម គឺឈ្មោះកម្រាលវិសេសមួយប្រភេទវិចិត្រដោយពណ៌ និងក្បាច់របនាផ្សេងៗ (ក្រាលព្រំ) ។

– **ព្រហ្ម** ជានាម ប្រែថាសេចក្តីចំរើន, ចំណែកចិត្ត ឬឈ្មោះទេវតាដែលកើតនៅព្រហ្មលោក (ព្រះ-ព្រហ្ម, ឋានព្រហ្ម) ។

២- ទារ.-

- **ទារ** ជាកិ. ប្រែថា ក្រើន តឿន បន្តឹងយកប្រាក់តាមកំណត់ដែលត្រូវបេញ, ត្រូវបង់ (ទារថ្លៃផ្ទះ) ។

- **ទា** ជានាម គឺឈ្មោះសត្វបក្សីស្រុកមួយមានម្រាមជើងជាប់គ្នា (ទាស្រុក, ទាព្រៃ) ។

៣- បទ.-

- **បទ** ជានាម ប្រែថា សំឡេងសូត្រ ឬ ច្រៀង (បទកាកគតិ, បទពាក្យ ៧) ។

- **បទ** ជានាម ប្រែថា ហេតុ, ចំណែកជាគ្រឿងដល់, ផ្លូវ, ស្នាមជើង (បទអញ្ញា, ធម្មបទ, សិក្ខាបទ) ។

- **បត់** ជាកិ. ប្រែថា ត្រឡប់តាមទំនង (បត់ដៃ, បត់ខោអាវ) ។

– **បថ** ជានាម ប្រែថា ផ្លូវ (ឥរិយាបថ, ជលបថ, កម្មបថ) ។

– **បត់** ជានាម ប្រែថា ផ្ទាំងពុទ្ធរូបគ្រូនឹងកំណាត់សំពត់ (ព្រះបត់) ។

– **បន** ជានិបាត ប្រែថា ដ្បិត (ប្រពន្ធឃើញឃាត់ទៅ ប្ដីមិនត្រូវថាកុំអ្នក ឯងខឹងលោភយឆាក់ ដោយចិត្តធំបទបានស្រា) ។

x

x x

## ទី១២– ថ្មចេះភាសាមនុស្ស

ប្រាសាទសិលាខ្មែរទាំងប៉ុន្មាន សុទ្ធសឹងតែចេះភាសាមនុស្ស ។ ចំពោះពាក្យនេះ អ្នកផងមុខជាមិនជឿជាដាច់អហង្ការ ព្រោះថា ថ្មជាវត្ថុគ សូម្បីតែគេគោះវាដោយដំបងក៏ដោយ ក៏វាមិនលាន់សូរដែរ ។ បើដូច្នេះ ហេតុអ្វីក៏ថាថ្មចេះភាសាមនុស្ស ?

មែនពិត អ្នកមិនដែលឮថានិយាយ ពីព្រោះអ្នកយល់ថា បុរាណកណ្ឌ តាំងឡាយនោះបានមកពីទេវតាបង្កើតឲ្យ ឬមកពីព្រះពិស្ណុការកសាងឲ្យ ។ ប៉ុន្តែបើអ្នកតាំងចិត្តជឿឲ្យស៊ប់ថាកេរ្តិ៍មត៌កតាំងនេះ ពិតជាស្នាដៃរបស់មនុស្ស ហើយមនុស្សនោះជាតិជាខ្មែរទៀត នោះថ្មគ្រប់ដុំនឹងនិយាយរកអ្នក ដោយរីករាយក្រាម ។ កុំចាំបាច់និយាយថ្វីដល់ទៅកំពូលត្រីសូល៍តាន់ឃ្លាយដែលខ្ពស់ត្រដឹម ព្វង់វហាស់នោះឡើយ សូម្បីតែក្រវិលតូចមួយ ក៏អាចប្រាប់អ្នកបានថា វិស្វករនិងជាងជួរកន្លងជំនាន់នោះ មានចំនួននិងចំណេះជាអនេកអនន្តយ៉ាងណាដែរ ។

ចូរអ្នកអញ្ជើញទៅទស្សនាប្រាសាទតាព្រហ្មហលមើល អ្នកនឹងឮសិង្ហនៅទីនោះ អតិប្រាយពង្សាវតារនៃប្រទេសយើងកន្លងយុគនោះប្រាប់អ្នក មុខគួរឲ្យអ្នកនឹកអាណោចអាធ័មដល់ក័ព្យាសនានៃមហានគរមិនខាន ។ ប៉ុន្តែបើអ្នកបានឮថាពជ-ជានីរបស់យើងដ៏រុងរឿងកន្លងបុរាណកាលនោះ ក្លាយមកជារី-

ហារដ្ឋាននៃម្រឹគពាឡ ហើយអយ័អគ្គសិលាសោត ក៏ក្លាយមកជាថ្មសំលៀងកាំបិតនៃពាលគង្វាលគោ តើបេះដូងអ្នកនឹងញាប់ញ័រដូចម្ដេចទៅ ? ខ្ញុំសូមបញ្ជាក់ថា សូរស័ព្ទនៃសំដីថ្មនោះ មិនមែនលាន់ចេញពីដ័រនៃចិត្តនៃជនណាដែលយកថ្មនោះមកធ្វើជាកសិណ ។

## សំនួរ

១– **ចូរពន្យល់ពាក្យ** បុកណកណ្ឌា, យុគ, អា·ណោចអាធ័ម, ម្រឹគពាឡ, កសិណ ។

២– **ពាក្យ«អហង្ការ, វេហាស៍, ត័ព្វ, ឫ·រាវណ»** អាចសរសេរបានពីរយ៉ាងដោយឥតខុស ។ ដូច្នេះចូរអ្នកសរសេរពាក្យទាំងនោះតាមបែបម្យ៉ាងទៀតនោះ ។

៣– **ចូរសម្គាល់ពាក្យ** ដាច់អហង្ការ, គ, មនុស្ស, (ស្នាដៃមនុស្ស), ក៏ (ក៏អាចប្រាប់អ្នក), នៃ (នៃប្រទេសយើង) ។

៤– ថ្មខាងត្បូង គួរចុះហេតុអ្វីក៏ថា ជាភាសាមនុស្ស?

មធ្យមសិក្សាប័ត្រ

លើកទី ២ ថ្ងៃ ៨-៧-៦៣

## កំណត់ចំណាំ

## ១– ពន្យល់ពាក្យ.–

– **បុរាណភណ្ឌ** (មកពីបុរាណ + ភណ្ឌ (ភណ្ឌ ប្រែថា វត្ថុ, ទ្រព្យ, របស់, គ្រឿងប្រដាប់) = វត្ថុពីបុរាណ (objet antique, objet ancien) ។

– **យុគ** (អាយុ, កាល, គ្រា, សម័យ (époque) ។ តាមបុរាណថា យុគមាន ៤ គឺ ទី ១= ក្រឹតយុគ (យុគមាស, អាយុមាស) មានកំណត់ត្រឹម ១.៧២៨ ០០០ឆ្នាំមនុស្ស; ទី២= ត្រេតយុគឬ ត្រេតាយុគ (យុគប្រាក់, អាយុប្រាក់) មាន កំណត់ត្រឹម ១.២៩៦.០០០ឆ្នាំមនុស្ស; ទី ៣= ទ្វាបរយុគ (យុគមានចំនួនលេខពីរ ៗ គឺលេខ

គត់គូ) មានកំណត់ត្រឹម ៨៦៤.០០០ ឆ្នាំ មនុស្សទិនទី៤ = កលិយុគ (យុគប្រកបដោយទោស, ប្រកបដោយជម្លោះ) មានកំណត់ត្រឹម ៤៣២.០០០ ឆ្នាំមនុស្ស ។

– អារណោចអាធ័ម (គុ) ស្រណោច បន្ទាប់ក្រពេក គឺមានចិត្តពោរពេញដោយទុក្ខ តឹងស្ទើរប្រេះទ្រូង ។

– ម្រឹកពាឡ (ន-) ម្រឹគសាហាវ, កាច (le fauve)

– កសិណ (ន.) រូបតាងជាសំគាល់ ។

២- អក្ខរាវិរុទ្ធ .-

– អហង្ការ (សរសេរមាន រ ចុង) ។

– សូម្បី (កុំសរសេរ សូមបី ដូច្នេះឲ្យសោះ) ។

– សូរ្យ (សរសេរមាន រ ចុង) ។

– ត្រីសូល៍ (សូល៍ សរសេរ សូ និង ល៍ ។ គេគាបសរសេរ ត្រីសូរ ដូច្នេះបាន) ។

- **សិទ្ធ** (សរសេរ ស្ និង ស្រៈ ិ ហើយនិង ទ្ធ) ។
- **ពាឡ្យម្រឹគ** (អាចសរសេរ វាឡ្យម្រឹគ ដូច្នេះបាន) ។
- **ពន្ធនាគារ** (គារ សរសេរមាន រ ចុង) ។
- **អារណោចអាធ័ម** (សរសេរ អា មិនមែន អ ទេ) ។
- **វាសនា** (មិនសរសេរ វាស្នា ដូច្នេះទេ) ។
- **បុរាណ** (អាចសរសេរ បូរាណ ដូច្នេះបាន) ។
- **អយ័អគ្គ** (ពាក្យ ២ ម៉ាត់នេះ សរសេរ និងមាន ន័យខុសគ្នា ។ អយ៍ < អយ "បាប, សេចក្ដីទុក្ខ" ។ អគ្គ ឬ អគ្រ ប្រែថា កំពូល, ខ្ពស់, លើស) ។
- **គង្វាល** (សរសេរទឹងស្រៈ -ា) ។
- **ជវ័ន** (សរសេរ វ័ និង ន) ។
- **កសិណ** (សរសេរ ក សិ និង ណ) ។

៣- **សទិសសព្ទ** នៃពាក្យ :

១- ពាឡ.–

– **ពាឡ** ជាគុ. (អាចក្លាយមកជាពាល ប្រែថា កាច សាហាវ) (ពាឡម្រឹគ ឬ វាឡម្រឹគ) ។

– **ពាល** ជាគុ. ប្រែថា ទន់, ដែលនៅក្មេង, ល្ងង់ខ្លៅ, កាច, សាហាវ, អាក្រក់ (ព្រះអាទិត្យពាល គឺដែលទើបរះមានពន្លឺនៅស្រទន់, ក្មេងកំពុងពាល) ។

២- គ.–

– **គ** ជាគុ. ប្រែថាឥតសំដី (មនុស្សគ) ។

– **គ** ជានាម គឺឈ្មោះឈើ ផ្លែវាមានសរសៃជាប៉ុយសំឡី (សំឡីគ) ។

– **គរ** ជាកិ. គឺធ្វើឲ្យជាគំនរ ។

**ចំណាំ** : ពាក្យផ្សំនឹង គ មុខ ដែលមិនសរសេរជាមួយ ៗ គឺមាន :

– គគាប, គគាត, គគីរ, គគឹក, គគឹត, គគុក, គគុកគគាក់, គគុល, គគុះ, គគើម, គគ្រក់, គគ្រទ់, គគ្រាក់, គគ្រាត, គគ្រិងគគ្រាំង, គគ្រិប, គគ្រិះ, គគ្រីតគគ្រាត, គគ្រីវ, គគ្រីស គគ្រូស, គគ្រឹក, គគ្រឹកគគ្រេង, គគ្រឹម, គគ្រឹត, គគ្រុក, គគ្រុម, គគ្រុយ, គគ្រូក, គគ្រួប, គគ្រើម, គគ្រេង, គគ្រេងគគ្រាំ, គគ្រោក, គគ្រាំ, គគ្រាំង, គឃរ, គឃារ, គឃឹក, គឃូស, គឃៀរ, គឃើន ។

៣- ភណ្ឌ :

– **ភណ្ឌ** ឬ **ភណ្ឌៈ** ជានាម ប្រែថា ទ្រព្យ, របស់ ដើមទុន, ឥវ៉ាន់, ប្រដាប់ (បុកណកណ្ឌ) ។

– **ភ័ន្ត** ឬ **ភាន់** ជាកិ. គឺជ្រួស, ច្រឡំ, ខុសទំនង (ភាន់គំនិត, ភាន់ផ្លូវ) ។

៤- លាង :

- **លាង** ជាកិ. គឺជម្រុះ, សម្អាត (លាងដៃ) ។
- **លៀង** ជាកិ. គឺចិញ្ចឹម, ចិញ្ចឹមរក្សា (លៀងជីវិត, ស៊ីលៀង, លៀងអារក្ស) ។
- **លៀងតា** ជានាម គឺឈ្មោះសត្វចតុប្បាទព្រៃមួយប្រភេទ រូបរាងស្រដៀងនឹងសត្វកែះ តែមាឌតូចជាង ។

x

x x

## ទី១៣- កម្ពុជាជាប្រទេសសុខសាន្ត

ព្រឹត្តិការណ៍ផ្សេងៗនៃពិភពលោក ចេះតែលេចឡើងបន្តបន្ទាប់គ្នា ដោយហេតុអ្នកនយោបាយ ដែលជាមគ្គុទ្ទេសក៍របស់ប្រទេសទាំងឡាយមានទស្សនៈនិងឧត្តមគតិពុំស្របគ្នា ។ អ្នកខ្លះប្រាថ្នាដឹកនាំប្រទេសជាតិទៅតាមមាគ៌ានយោបាយបែបនេះ ខ្លះទៀតចង់ទៅតាមគន្លងនោះវិញ ។ យោបល់មិនស្រប

គ្នានេះ នាំឲ្យកើតមានវិបត្តិនិងបង្កបង្កើតវេរាន់គ្នាឯង ៗ

ក្នុងទេសកាលៈបច្ចុប្បន្ននេះ ប្រទេសខ្លះនៅអាស៊ីទ្វីបភាគអាគ្នេយ៍ជិតខាងយើងកំពុងតែជួបនឹងអសន្តិសុខ ទុក្ខព្រួសពេញលើផ្ទៃប្រទេស មានតែប្រទេសកម្ពុជាអព្យាក្រឹតមួយប៉ុណ្ណោះទេដែលបានទទួលនូវសុខសន្តិភាព សម្បូណ៌សប្បាយតែម្នាក់ឯង ៗ ក្នុងឱកាសដែលស្នូរគាំភ្លើង គ្រាប់បែកកំពុងផ្ទុះនៅក្នុងប្រទេសជិតខាងយើង គេឃើញមានចម្រៀងកំរែកសំណើចក្អាកក្អាយ ក្នុងការប្រកបរបរអាជីវទ្រព្យ៍នៃពលរដ្ឋខ្មែរផនបរទេសខ្លះ ដែលធ្លាប់តែជឿសំដីសប្បុរសរបស់ប្រទេសដែលជាអមិត្តនឹងកម្ពុជា កាលបើបានជាន់ដីខ្មែរពេលណា ក៏ស្រាប់តែភ្ញាក់អាត្មាស្រឡាំងកាំង ដោយឃើញប្រទេសខ្មែរសម្បូណ៌សប្បាយ មានវឌ្ឍនភាពគ្រប់មជ្ឈដ្ឋាន ៗ បុរេវិនិច្ឆ័យដែលកើតពីការជុំគ្រវៀកនៃប្រទេសអក័ព្វទាំងនោះ ក៏ត្រូវរលាយសូន្យទៅដូចអំបិលត្រូវទឹក ៗ អ្នកទេសចរ អ្នកយកពត៌មាន អ្នកពិនិត្យការណ៍គ្រប់សព្ទាត៌ គ្រប់ពណ៌នយោបាយ

ដែលមកកាន់ប្រទេសខ្មែរ តែងបានទទួលកក្តីភាព សមានចិត្ត និងការឧបត្ថម្ភស្មើមុខគ្នាពីអ្នកកាន់អំណាចខ្មែរ ។

សុខសន្តិភាព វឌ្ឍនភាព និងកិត្តិសព្ទជាអាទិ នៃប្រទេសខ្មែរនេះ ពិតជាលទ្ធផលដែលបានហូរមកតាមព្រះរាជនយោបាយដ៏ភ្លឺស្វាងនៃព្រះប្រមុខរដ្ឋខ្មែរជាប្រាកដ ។ ព្រះអង្គពុំមែនយកព្រះទ័យទុកដាក់តែនឹងសេចក្តីសុខសាន្ត និងសុខុមាលភាពនៃប្រជាពលរដ្ឋព្រះអង្គតែប៉ុណ្ណោះទេ គឺរហូតដល់សន្តិភាពសកលលោកទៀតផង មានភស្តុតាងនាសន្និសីទនៅក្រុងហ្សឺណែវ និងអង្គការសហប្រជាជាតិជាសក្ខីភាពស្រាប់ ។

**ឈយន - វឿម**

សំនួរ

១- **ចូរពន្យល់ពាក្យ** ព្រឹត្តិការណ៍, ឧត្តមគតិ, បដិបក្ស, បុរេវិនិច្ឆ័យ, សមានចិត្ត, សក្ខីភាព ។

២- **ចូរស្រង់នូវសកម្មកិរិយា** និងអកម្មកិរិយាខ្លះ ដែលមាននៅក្នុងអត្ថបទនេះ ហើយ

បញ្ជាក់ពីរបៀបប្រើកិរិយានេះផង ។

៣- **ចូររកសទិសសព្ទ** នឹងពាក្យ " ឬ " ព្រម

តាំងឃ្លាបញ្ជាក់ផង ។

៤- **តើចំពោះព្រះរាជសកម្មភាព** យ៉ាងណា

ខ្លះ ដែលប្រជាពលរដ្ឋយើងបានថ្វាយនាម

ដល់សម្ដេចឪថាជា **ព្រះបិតាសន្តិសុខ**

**ជាតិ** និងសកលលោកផង ? ។

មធ្យមសិក្សាប័ត្រ

លើកទី១ ថ្ងៃ ១៤-៥-៦៤

## កំណត់បំណាំ

១- **ពន្យល់ពាក្យ**.-

– **ព្រឹត្តិការណ៍** (ន.) ហេតុ ឬដំណើរដែលប្រ

ព្រឹត្តទៅតាមប្រក្រតី ( l'événement ) ។

– **ឧត្តមគតិ** (ន.) គតិឧត្តម ឬដំណើរកើតល្អ, ចិត្ត

គំនិតខ្ពង់ខ្ពស់, អធ្យាស្រ័យដែលដុះចេញមក

ដើម្បីរិះរកសេចក្ដីសុខ-ចម្រើន, ឬគោលបំណង

ចង់ឲ្យបានល្អប្រពៃ (l'idéal) ។

– **បដិបក្ស** (គុ.) ដែលផ្ទុយនឹង, ដែលជំទាស់ មិនស្របជាមួយ (ennemi, opposant) ។

– **បុរេវិនិច្ឆ័យ** (ស.ន.) ការវិនិច្ឆ័យដោយគ្មានពិចារណា, ដោយងងឹតងងល់, ការវិនិច្ឆ័យដោយស្មាន រវើរវាយ ។

– **សមានចិត្ត** (ស.ន.) ចិត្តស្មោះស្មើ, ចិត្តដែលមានសភាពទោរទន់រកគ្នា ដោយសេចក្ដីស្រឡាញ់ ។

– **សក្ខីភាព** (ន.) ដំណើរជាសាក្សី (le témoignage, la preuve)

២. **អក្ខរាវិរុទ្ធ**.–

– **បដិបក្ស** (អាចសរសេរជា បដិបក្ខ ប្រតិបក្ស ដូច្នេះបាន) ។

– **ទេសភាលៈ** (ទេសកាលៈ សរសេរ យុគល

ពិន្ទុ តែក្រោយ កាលៈទេ ។ បើថា កាល-
ទេសៈក៏បាន ) ។

- **អាវគ្ឈ័យ** ( សរសេរ អា គ្ឈេ និង យ៍ ) ។
- **ទុរ្ភិក្ស** ( អាចសរសេរ ទុព្ភិក្ខ ដូច្នេះក៏បាន ។
 គេសរសេរទើងស្រៈ ិ ) ។
- **អព្យាក្រឹត** ( សរសេរ ក្រ ស្រៈ ឹ និង ត ) ។
- **ចម្រៀង** ( សរសេរតម្រួត មកពី ច្រៀង ។
 ពីមុនអាចសរសេរ ចំរៀង បាន ) ។
- **អចិន្ត្រៃយ៍** ( សរសេរ អ ចិ ន្ត្រៃ និង យ៍ ) ។
- **ឬទេ** ( អានថា ប៊ុ ទេ ) ។
- **អភ័ព្វ** ( អាចសរសេរ អភព្វ ឬ អភ័ព្យ ដូច្នេះក៏
 បាន ) ។
- **ឧបត្ថម្ភ** ( កុំច្រឡំនឹង ឧបត្ថម្ភក ជានាម ប្រែថា
 អ្នកទំនុកបម្រុង ) ។

## ៣- សទិសសព្ទ នៃពាក្យ :

### ១- លិច .-

- **លិច** ជាកិ. ប្រែថា លិចចុះបាត់ទៅ, ចូលកប់បាត់ទៅក្នុងទឹក (ទូកលិច, ព្រះអាទិត្យលិច, លិចខ្លួន) ។

- **លិច** ជានាម គឺឈ្មោះទិសដែលព្រះអាទិត្យអស្តង្គត (ទិសខាងលិច, នៅឯលិច) ។

- **លេច** ជាកិ. គឺចេញពីទីកំបាំង (ស្រាប់តែឃើញលេចភ្លឹមពីក្នុងព្រៃមក); ជ្រាបហូរចូល (ទឹកលេចពីភ្លឺស្រែ); លៀនចេញ (គ្រាប់ឈើដុះលេចពន្លកពីក្នុងដី); ក្លាយ, ផ្សាយចេញ (លេចដំណឹង) ។

- **លេច** ជាគុ. ប្រែថា ដែលមិនគត់ (ក្អមលេច, ផ្ទះលេច); មាត់រអិល (មាត់លេច) ។

- **លេច** ជានាម គឺឈ្មោះដំបៅកើតនៅបាតជើង

(ដំឡើងលេខ) ។

២- សូន្យ .—

- **សូន្យ** ជាគុ. ប្រែថា ទទេ, ឥត, សោះទទេ (សូន្យឈឹង, សូន្យសោះ, សូន្យសុង)

- **សូន្យ** ជានាម គឺភាវៈទទេ, ពិន្ទុ ឬ ក្បៀស, និគ្គហិត (សូន្យ ១, សូន្យ ២)

- **សូន** ជាកិ. គឺប្រមូលអ្វីៗដែលមានសាច់ទន់ជ្រាយឲ្យកើតជាដុំ, ជាគ្រាប់, ជារូប, (សូនគុលិកា, សូនរូប, សូនទៀន) ។

x

x x

## ទី១៤- យុវជនខ្មែរ

យុវជនខ្មែរទាំងអស់ ទោះប្រុសក្ដី ស្រីក្ដី ជាកម្លាំងមួយផ្នែកយ៉ាងសំខាន់ក្នុងការបម្រើប្រទេសជាតិមាតុភូមិ ។ យុវជនយើងត្រូវតាំងសតិសម្បជញ្ញៈឲ្យភ្ញាក់រលឹកជានិច្ច ព្រមទាំង

មានសតិអារម្មណ៍ខ្ពង់ខ្ពស់ប្រសើរឧត្តុង្គឧត្តម ៗ តែត្រូវមានសន្តានចិត្តចេះសន្តោស មានអធ្យាស្រ័យបរិសុទ្ធហ្មត់ហ្មង់ចេះសាមគ្គីជិតស្និទ្ធស្រឡាញ់រាប់អានគេមិត្តភក្តិ មិនប្រទូស្តប្រមាថមើលងាយយុវជនដទៃ មិនសេពគប់ស្មគ្រស្មាគមជាមួយនឹងមនុស្សពាលអបលក្ខណ៍ និងមិនប្រព្រឹត្តលេងល្បែងពាលាដែលនាំមកនូវទោសពៃរ៍ដល់ខ្លួនឡើយ ៗ

នៅតាមជនបទស្រែចំការ ឬនៅតាមរោងចក្រឧស្សាហកម្ម យុវជនជាកសិករ ឬ កម្មករត្រូវតែបញ្ចេញសមត្ថភាពឲ្យអស់ពីចិត្ត ប្រឹងប្រែងរស់រវើកប្រកបការងារដែលជាកាតព្វកិច្ចរបស់ខ្លួន មិនស្ទាក់ស្ទើរ ឬ ត្អូញត្អែរ ដោយខិតខំបង្កើតផលិតផលគ្រប់ដំពូក ឲ្យបានសម្បូណ៌ហូរហៀរច្រើនជាអនេកប្បការ ដើម្បីសាងសេដ្ឋកិច្ចជាតិឲ្យបានចំរើនលូតលាស់ឆាប់រហ័សទាន់សម័យនិយម ៗ

នៅតាមអាគារសិក្សា យុវជនអ្នកសិក្សាកាមត្រូវតែព្យាយាមរៀនសូត្រសព្វសាស្ត្រវិជ្ជាតាមក្រិត្យក្រម ដើម្បីបណ្តុះ

និស្ស័យ កសិនារបស់ខ្លួនឲ្យទៅជាអ្នកចេះដឹងឈ្លាសវៃ ឬជាអ្នកប្រាជ្ញបណ្ឌិតយ៉ាងចំណានក្នុងពេលអនាគត ។

នៅក្នុងគ្រាសាសនាដែលមានទាំងសត្រូវចូលលុកលុយទន្ទ្រានប្រទេសជាតិ យុវជនទាំងអស់ត្រូវតែធ្វើពលីកម្មចេញតយុទ្ធតទល់យ៉ាងអង់អាចជាមួយបច្ចាមិត្រ លុះត្រាតែដណ្ដើមបានជោគជ័យជាអវសាន ។

យុវជនខ្មែរមិនត្រូវបណ្ដែតបណ្ដោយ ធ្វើឲ្យជីវិតដ៏មានតម្លៃរបស់ខ្លួនដែលប្រៀបបានទៅបុប្ផាកំពុងរីកស្គុសស្គាយផ្សព្វផ្សាយក្លិនគន្ធពិដោរនោះឲ្យស្រពោនវិញបានឡើយ ។ ដោយសារកម្លាំងដ៏រឹងប៉ឹងយ៉ាងប្រឡូកនៃយុវជននេះ ប្រទេសកម្ពុជានឹងបានទទួលអាយុធម៌ ព្រមទាំងវឌ្ឍនធម៌ថ្មីតទៅ កាលយូរអង្វែង ដូចមហាប្រទេសស៊ីវិល័យនានាក្នុងសកលលោក ។

## សំនួរ

**១– ចូរពន្យល់ពាក្យ** សតិសម្បជញ្ញៈ, សមគ្គីភាព, ភាតតញ្ញូកិច្ច, ពលីកម្ម, ប្រឡូក ។

២- ចូររកសទិសសព្ទនៃពាក្យ "ការ" ។

៣- យុវជនម្នាក់ៗ មានករណីយកិច្ចយ៉ាងណា?

មធ្យមសិក្សាប័ត្រ

( លើកទី ២ ខែ ៦-៨-៦៤ )

## កំណត់ចំណាំ

១- ពន្យល់ពាក្យ :

- សតិសម្បជញ្ញៈ ស្មារតីនិងសេចក្ដីដឹងខ្លួន ។
- សមត្ថភាព ភាពនៃសេចក្ដីអាចហាន, សេចក្ដីមោះមុត ។
- ភារកិច្ច ករណីយកិច្ច, កិច្ចដែលគួរធ្វើ, ការងារដែលត្រូវតែធ្វើ ។
- ពលីកម្ម ការបូជា, ការសង្គ្រោះ ។
- ប្រត្យក្ស ( ឬ ប្រចក្ស) ដែលជាក់, ប្រាកដ, ច្បាស់, មែន, ពិត ។

២- អក្ខរាវិរុទ្ធ .–

- **កម្លាំង** (សរសេរតម្រួត ព្រោះមកពី ខ្លាំង ។ ពីមុនអាចសរសេរ កំឡាំង បាន) ។
- **បម្រើ** (សរសេរតម្រួត ព្រោះមកពី ប្រើ ។ ពីមុនអាចសរសេរ បំរើ បាន) ។
- **និច្ច** (សរសេរ និ នឹង ច្ច) ។
- **សន្តាន, សន្តោស** (សរសេរប្រកបនឹង ន ជើង ត) ។
- **ម៉ត់ម៉ង** (អាចសរសេរ ម៉ត់ហ្មង ឬ ហ្មត់ហ្មង បាន) ។
- **ស្ម័គ្រស្មាគម** (ស្ម័គ្រ សរសេរ ស្ម័ នឹង គ្រ ។ ស្មាគម សរសេរ ស្មា – គ នឹង ម) ។
- **ទោសពៃរ៍** (ពៃរ៍ សរសេរ ពៃ នឹង រ៍) ។
- **វៀសវៃ** (វៀស សរសេរ នឹង ស្រៈ –ៀ ។ វៃ សរសេរ វ ស្រៈ ៃ– ) ។
- **ឥស្សីរ** (មាន រ ចុង) ។

- វិត្ថារ (មាន រ ចុង) ។
- ចំពូក (អាចសរសេរ បំពូក បាន) ។
- ហួរហៀរ (សុទ្ធតែមាន រ ចុង) ។
- អាគារ (សរសេរ អា និង គារ (មាន រ ចុង) ។ មិនមែន អគារ ទេ ។
- ឈ្លាសវៃ (សរសេរ ឈ្លា និង ស ។ វៃ សរសេរស្រៈ ៃ-) ។
- ពុះពារ (សរសេរ រ ចុង ។ ស្រៈ -ា) ។
- ផ្សព្វ (សរសេរ ផ្ស និង ព្វ) ។

៣- សទិសសព្ទ នៃពាក្យ :

១- សូត្រ .—

- សូត្រ ជានាម ប្រែថា ចេស, ខ្សែធ្មារ, សរសៃធ្មារល្អិត (ក្រាស់សូត្រ, សំពត់សូត្រ) ។
- សូត្រ ជានាម គឺពុទ្ធវចនៈចំណែកមួយ (ព្រះសូត្រ)—គោលរបស់ការសិក្សាសម្រាប់ទន្ទេញ

ឲ្យចាំ (គោលសូត្រ, មេសូត្រ) ។

- **សូត្រ** ជាកិ. ថាតាមរបៀបពាក្យដែលទន្ទេញចាំមាត់ (សូត្រធម៌, សូត្រអាគម) ។

- **សូត** ជានាម ប្រែថា សារថី, អ្នកបររថ, សំដីសម្តែងអំណារ, ការថ្លែងអំណារ ។

- **សូទ** ឬ **សូទៈ** ជានាម ប្រែថា អ្នកចំអិនអាហារ, អ្នកធ្វើម្ហូប (សូទកម្ម, សូទវិជ្ជា) ។

- **សូទ្រ** ឬ **សូទ្រៈ** ជានាម គឺមនុស្សកើតក្នុងវណ្ណៈទី៤, អ្នកងារ (ពួកសូទ្រ) ។

២- វៃ .-

- **វៃ** ជាគុ. ប្រែថា ឆាប់, រហ័ស, ក្លាហាន, ឆាប់ក្លាហាន (ឆាប់វៃ, ទៅវៃៗ) - ឈ្លាស, ស្ទាត់ប្រាកដ, ជំនាញ, ប៉ិន (ប្រាជ្ញាវៃ, ត្រចៀកវៃ, ភ្នែកវៃ) ។

- **វ័យ** ឬ **វយៈ** ជានាម ប្រែថា អាយុ, កំណត់អាយុ (វ័យក្មេង, បឋមវ័យ) ។

៣_ ពារ ._

– **ពារ** ជាកិ. ប្រែថា ប៉ះលើ (ពាររបង) ។

– **ពារ** ជានាម ប្រែថា ថ្ងៃ (ពារពុធ) ។

– **ពៀរ** ជានាម ប្រែថា បំណងចិត្តជាសត្រូវ (បងពៀរ, ពៀរវេរា) ។

៤_ ខាន់ ._

– **ខាន់** (មកពីពាក្យ **ខ័ឌ ឬ ខ័ឌ្គ**) ជានាម ប្រែថា គ្រឿងសស្ត្រាមួយប្រភេទ ផ្លែមានមុខទាំង ២ ខាង (ព្រះខ័ន ឬ ព្រះខាន់) ។

– **ខណ្ឌ** ជានាម ប្រែថា សង្កាត់, ប៉ែក, កំណាត់, ប៉ែកអាណាខែត្រ (ខណ្ឌភ្នំពេញ) ។ សព្វថ្ងៃ គេប្រើពាក្យ ស្រុក ជាជំនួសខ័ណ្ឌវិញ ។

– **ខណ្ឌ** ជានាម ប្រែថា កម្រិត, បម្រាមផ្តាច់មិនឲ្យធ្វើ (ទៅបាន ឥតមានខណ្ឌទេ) ។

- **ខន្ធ** ជានាម ប្រែថា ក, ដើម, គំនរ, ពួក, កង, កំណាត់ (ខន្ធ៥, រំលត់ខន្ធ) ។

**សង្កេត** .-

១- ពាក្យសរសេរមាន ខាន់ ពីមុខ គឺ :

- ខាន់ទៅ, ខាន់ជិប, ខាន់លឿន, ខាន់ស្លា, ខាន់ស្លាក ។

២- ពាក្យសរសេរមាន ខណ្ឌ ពីមុខ គឺ :

- ខណ្ឌខាប់, ខណ្ឌសញ្ញា, ខណ្ឌស្ករ, ខណ្ឌសីមា ។

x

x x

## ទី១៥- ប្រទីបអក្សរសាស្ត្រ

អក្សរសាស្ត្រជាអរូបនាមមួយផ្នែកដែលមានន័យលក្ខណៈដំឡូលំឡូលាយសម្រាប់បណ្ដុះនូវនិស្ស័យវប្បធម៌ នៅក្នុងខន្ធសន្ដានៃសត្តនិករទូទៅ ។

អក្សរសាស្ត្រជាសាខាមួយផ្នែកក្នុងរឿងវប្បធម៌ ដែលជាសភាពការណ៍ម្យ៉ាងផ្តល់នូវអារ្យធម៌និងវឌ្ឍនធម៌ដល់មនុស្សនិករទូទាំងពិភពសាកល ។ អរូបនាមនេះ មានឫទ្ធានុភាពដ៏សក្តិសិទ្ធិ និងជាអតិបរមាក្នុងការសំគាល់នូវការវិវឌ្ឍន៍នៃមនុស្សម្នាក់ៗ ។ ជនណាប្រកបដោយអក្សរសាស្ត្រនៅក្នុងខ្លួន ពោលគឺជនណាប្រកបដោយចំណេះវិជ្ជាជ្រៅៗ គេតែងសន្មតថាជននោះមានទស្សនៈភ្លឺស្វាង ហើយទទួលនូវសេចក្តីថ្លៃថ្នូរជាមិនខាន ឲ្យតែចំណេះវិជ្ជានោះឈរនៅលើគោលលក្ខណៈល្អ ព្រោះថា “ ចំណេះវិជ្ជានាំឲ្យមានទ្រព្យសម្បត្តិ ទ្រព្យសម្បត្តិផ្តល់នូវសេចក្តីសុខចំរើន សេចក្តីសុខចំរើននាំឲ្យមនុស្សទទួលនូវសេចក្តីថ្លៃថ្នូរ ” ។

ទន្ទឹមនឹងនេះ យើងឃើញថា អក្សរសាស្ត្រជាទឹកទិព្វអម្រឹតដ៏មានមហិទ្ធិឫទ្ធិជាមហស្ចារ្យម្យ៉ាង អាចប្រោះព្រំពង្សមនុស្សឲ្យសុះវិវត្តទៅរកសេចក្តីចំរើន និងសេចក្តីថ្លៃថ្នូរបាន ។ គេតែងសំគាល់វឌ្ឍនភាពរដ្ឋនីមួយៗស្របទៅតាមដំណើរវប្ប-

ធម៌ឬអក្សរសាស្ត្រនៃប្រទេសនោះ ព្រោះថាវឌ្ឍនភាពគ្រប់វិស័យថិតទៅតាមទម្រង់វប្បធម៌ ឬដូចប្រជាភាសិតជាសក្ខីភាពថា "អក្សរលត់ ជាតិគឺរលាយ" យ៉ាងនោះដែរ ។

ម្យ៉ាងទៀត តាមដំណើរខាងលើនេះ សម្តេចព្រះអគ្គមគ្គុទ្ទេសក៍ ដែលជាព្រះបិតាវប្បធម៌ជាតិបានឈ្វេងយល់និងចាត់វិធានការថ្មី គឺអក្ខរបនីយកម្ម ដើម្បីបំបាត់អនក្ខរភាពពីដួងសតិស្មារតីប្រជាពលករមួយចំនួន ដែលងងឹតងងល់នៅឡើយ ។

ព្រះរាជវិធានការថ្មីៗ នេះ ត្រូវបានទទួលការគាំទ្រយ៉ាងសកម្មនិងពេញទំហឹងពីគ្រប់មជ្ឈដ្ឋានប្រជាពលរដ្ឋខ្មែរ ។

## សំនួរ

**១- ពន្យល់ពាក្យ** ខន្ធសន្ដាន, វប្បធម៌, សត្តនិករ, សក្ខីភាព, អក្ខរបនីយកម្ម, អនក្ខរភាព ។

**២- ដូចម្តេចដែលហៅថានាមនាម?** ចូររកនាមនាមទាំងនោះដោយទាញឧទាហរណ៍

នៅក្នុងអត្ថបទនេះ ។

៣- **ចូរសម្ពន្ធពាក្យ** ក្នុងឃ្លា : "អក្សរលេត ជាតិគិរណាយ" ។

មធ្យមសិក្សាប័ត្រ

លើកទី ១ ថ្ងៃ ៣-៦. ៦៥

## កំណត់ចំណាំ

១- **ពន្យល់ពាក្យ** .–

– **ខន្ធសន្តាន** កំណើតពូជពង្ស, ប្រជុំទឹកចិត្ត ។

– **វប្បធម៌** ការផ្ដុំបណ្ដុះវិជ្ជា និងប្រាជ្ញាស្មារតីឲ្យបានចំរើនល្អលាស់ដោយវិទ្យាសាស្ត្រ ឬដោយសិល្បៈផ្សេងៗជាដើម (la culture) ។

– **សត្វនិករ** ពួកសត្វទាំងពួង (គឺមនុស្សសត្វនៅលើលោកនេះ) ។

– **សក្ខីភាព** ដំណើរជាសាក្សី (la preuve) ។

– **អក្ខរូបនីយកម្ម** ដំណើរ ឬការរៀបចំបង្រៀន

អក្ខរ ឬអក្សរចំពោះប្រជាពលរដ្ឋទូទៅ alphabétisation ។

– **អនក្ខរភាព** ភាពមិនចេះអក្សរ analphabète ។

២- **អក្ខរាវិរុទ្ធ** .–

– **ការវិវឌ្ឍន៍** (វិវឌ្ឍន៍ សរសេរ ឍ ខាងចុង) ។

– **ថ្លៃថ្នូរ** (ថ្នូរ មាន រ ចុង) ។

– **ទិញ** (សរសេរ ទិ និង ញ) ។

– **ប្រោះព្រំ** (សរសេរ ប្រោ និង ស្រៈ ះ , ព្រំ សរសេរ ព្រ និងស្រៈ ំ ) ។

– **ល្បួង** (កុំច្រឡំនឹង ល្វែង) ។

៣- **សទិសសព្ទ** នៃពាក្យ :

១- ព្រោះ :

– **ព្រោះ** ជាកិ. ប្រែថា បាចគ្រាប់ពូជល្អិតៗ ដើម្បីឲ្យដុះលូតលាស់ឡើង (ព្រោះស្ពៃ, ព្រោះស្រូវ) ។

- **ព្រោះ** ជាឃា. ទិ. ប្រែថា ហេតុ ដ្បិត (រៀនពុំចេះ ព្រោះខ្ជិល, ព្រោះតែ) ។

- **ព្រោះ** ជាគុ. ប្រែថា ស្គាំ (គោព្រោះ គឺគោស្គាំ) ។

- **ព្រួស** ជាកិ. គឺបញ្ចេញទឹក ឬ ទឹកមាត់ពីក្នុងមាត់ឲ្យខ្ចាយព្រោង ដោយកម្លាំងខ្យល់ (ព្រួសទឹក, ពស់ព្រួសពិស) ។

x

x x

## ទី១៦- ឈមមុខទៅរកវឌ្ឍនភាព

ក្នុងអតីតកាល មាតុភូមិយើងធ្លាប់បានជាមហាអំណាចមួយក្នុងភូមិភាគសុវណ្ណភូមិ ដូចមានបុរាណវត្ថុ សិលាប្រាសាទដែលសេសសល់កត់កយនៅលើភូមិភាគនេះសព្វថ្ងៃ ជាសក្ខីភាពស្រាប់ ។

ប៉ុន្តែដោយហេតុតែមានសេចក្តីប្រមាទធ្វេស និងមាន

សាមគ្គីគេចរវេចន៍គ្នាឯងជាញឹកញយ ជាឱកាសឲ្យរដ្ឋជិតខាង ខ្វះ ដែលមានមហិច្ឆតាលោភលន់ចូលមកធ្វើទន្ទ្រានបំបះបំបោរពលរដ្ឋឲ្យក្បត់សតិសម្បជញ្ញៈធ្លាក់ក្នុងមិច្ឆាមគ្គ ៗ ឯពលានុភាពនៃរដ្ឋខ្មែរក៏ប្រែជាទន់ខ្សោយ ហើយនៅទីបំផុតក៏លង់ខ្លួនក្នុងទាសភាពនៃសាសន៍ស្បែកសទៀត ៗ តាំងពីពេលនោះមក អរិយធម៌និងវប្បធម៌ជាតិក៏គាប់អន់ស្ទើរទៅ ៗ ឯអរិយធម៌និងវប្បធម៌បរទេសត្រូវបានគេសាបព្រោះបណ្តុះឡើង ៗ

ក្នុងឆ្នាំ ១៩៤៣ សតវត្សរ៍ថ្មីបានចាប់ផ្តើមឡើង ៗ ស្មារតីភ្ញាក់រលឹកចំពោះសិទ្ធិសេរីភាពនិងឯករាជ្យជាតិ បានផុសលេចឡើងគ្រប់មជ្ឈដ្ឋាន ៗ ក្រោមព្រះកិច្ចដឹកនាំប្រយុទ្ធទាមទារនៃសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** មាតុភូមិយើងក៏បានឋានៈជាកុដិស្សភាពឡើងវិញ ៗ តាំងពីពេលនោះមក ខ្មែរទូទៅគ្រប់ឋានៈបានខិតខំស្ថាបនាប្រទេសជាតិ ដោយឥតសំចៃកម្លាំងឡើយ ៗ ក្នុងដំណើរទៅមុខនេះ ពលរដ្ឋគ្រប់រូបរួបរួមជុំវិញអង្គសម្តេចឪ បានពុះពារដោយក្លាហាន នូវឧបសគ្គបង្អាក់

ដំណើរវិវឌ្ឍន៍នៃមាតុភូមិយើង ។ សមិទ្ធិធំៗដែលជាលក្ខខណ្ឌចាំបាច់នៃឯករាជ្យជាតិក៏បានលេចផុសព្រោងព្រាតឡើង លើផ្ទៃអាណាចក្រកម្ពុជាយើងបីដូចជាគេជប់ដោយទិព្វមន្ត ។

## សំនួរ

**១. ចូរពន្យល់ពាក្យ** សក្ខីភាព, សាមគ្គី, មហិច្ឆតា, វិទ្ធង្សនា, មិច្ឆាមគ្គ, កុដិល្យភាព ។

**២– ចូររកពាក្យផ្ទុយនឹងពាក្យ** សាមគ្គីភេទ - អរិយធម៌ - កុដិល្យភាព ។

**៣– ចូររកវេវចនសព្ទ** នឹងពាក្យ : "ព្រោះ" សាបព្រោះ ហើយពន្យល់ន័យនៃពាក្យនោះផង ។

**៤. ពាក្យបែបណាហៅថា** នាមនាម ? សព្ទបែបណាហៅថាសមាសនាម ? ចូររកឧទាហរណ៍ក្នុងអត្ថបទឲ្យបានប្រាំ យ៉ាងតិច ។

មធ្យមសិក្សាប័ត្រ
លើកទី១ ថ្ងៃ ១៦-៥-៦៦

## កំណត់ចំណាំ

### ១- ពន្យល់ពាក្យ -

-- **សក្ខីភាព** ដំណើរជាសាក្សី (le témoignage, la preuve) ។

– **សាមគ្គី** សេចក្ដីព្រមព្រៀង, ដំណើរស្រុះគ្នា (la solidarité) ។

– **មហិច្ឆតា** សេចក្ដីប្រាថ្នាធំ, ការចង់បានច្រើន, សេចក្ដីលោភលន់ (l'ambition) ។

– **វិទ្ធង្សនា** (ម្ក វិទ្ធំសនា) ការកំចាត់បង់, ការបំផ្លិចបំផ្លាញ, អំពើបះបោរដើម្បីរំលំរំលើងរបបគ្រប់គ្រងរដ្ឋ (la subversion) ។

– **មិច្ឆាមគ្គ** ផ្លូវខុស, ផ្លូវដែលមិនពិត (le faux chemin) ។

– **ភុជិស្សភាព** (ម្ក ភុជិស្សតា) ភាពជាអ្នកជា, ដំណើរឥតជំពាក់បំណុលគេ (l'innocence) ។

២- អក្ខរាវិរុទ្ធ

- អរិយធម៌ (អាចសរសេរជា អារ្យធម៌ បាន) ។
- សតវត្ស (អាចសរសេរ សតវត្សរ៍ ដូច្នេះបាន) ។
- ផ្ទុស (សរសេរ ផ្ទុ មិន ស) ។
- ទាមទារ (ទារ មាន រ ចុង) ។
- ឋានៈ (សរសេរ ឋ មិន ឍ) ។
- ជប (សរសេរ ជ មិន ប ឥត បន្តក់ទេ) ។

៣- សទិសសព្ទនៃពាក្យ :

១- សេស :

- សេស ជាគុ. ប្រែថា ដែលសល់, ដែលឥតគូ (របស់សេស, លេខសេស) ។
- សេស ជានាម ប្រែថា សំណល់, របស់ជាដែល (អស់លើឥតមានសេស) ។
- សេស ជាកិ. ប្រែថា ដែលសល់ពីគេ, ក៏មានសល់ (អាហារសេសសល់, សេសមួយ) ។

- **សេះ** ជានាម គឺបសុសត្វបសុបាទ (សត្វសេះ, សេះទេស) ។

- **សេះ** ជានាម គឺឈ្មោះក្តាមសមុទ្រ (ក្តាមសេះ) ។

២- សាសន៍ :

- **សាសន៍** ជានាម (ពុទ្ធសាសន៍, សាសន៍ខ្មែរ) ។

- **សាស្ត្រ** ជានាម ប្រែថា គម្ពីរ, ច្បាប់, ក្បួន, តម្រា, វិជ្ជា (ប្រវត្តិសាស្ត្រ, វិទ្យាសាស្ត្រ) ។

- **សាស្ត្រ** ជានាម ពាក្យក្លាយមកពីសស្ត្រ សស្ត្រា (មុខសាស្ត្រ) ។

- **សះ** ជាកិ. គឺជាដំបៅ (សះដំបៅ, សះស្បើយ) ។

៣- ស :

- **ស** ជា គុ. គឺដែលមានសម្បុរដូចសំឡីកប្បាស (ពណ៌ស, សំពត់ស) ។

- **ស** ជា កិ. គឺចាក់ចុះព្រោះដោយស្ន (សត្រី) ។

– **ស** ជា កិ. គឺសង្កេតគេព្រាវៗ ដោយស្មានៗ ឲ្យឃើញ (ស គេឲ្យឃើញ) ។

– **សរ** ជានាម ប្រែថាព្រួញ, កាំ, កាំឆ្ប (ស្ដេចផ្ទងសរ, គ្រាប់សរ, កូនសរ) ។

– **សរ** ជា កិ. គឺរឭក, រឭកឃើញ, នឹកឃើញ, សារដឹងឡើងវិញ (សរជាតិ, សរញាណ) ។

**ចំណាំ**.–

ពាក្យសរសេរមាន សរ នៅពីមុខ គឺ:

– សរណៈ, សរទៈ, សរទកាល, សរពាគ្គ, សរពើ, សរពេជ្ញ, សរគណ្ឋ, សរសន់, សរសើរ, សរសេរ, សរសៃ ។

៤- ជប :

– **ជប** ជា កិ. ប្រែថា ខ្សឹប, ស្វាធ្យាយខ្សឹបៗ, សូត្រភយមន្តគាថាខ្សឹបៗ ឲ្យកើតបានជាអ្វីៗ តាមបំណង (ឥសីជប) ។

– **ជប់** ជា កិ. គឺជញ្ជក់, ស្រូប, បឺត (ម្ដាយជប់

បង្កើយកូន) ។

– **ជប់** ជានាម គឺកន្សែងដែលបិត ស្រូបយកទឹក (ជប់ក្នុំ) ។

**៤- ពាក្យផ្ទុយ** ទីន :

– **សាមគ្គីភេទ** គឺ **សាមគ្គីភាព**

(សាមគ្គីភេទប្រែថា ការបែកសាមគ្គី; អ្នកបំបែកសាមគ្គី ហៅសាមគ្គីភេទកៈ; ឯសាមគ្គី ឬ សាមគ្គីភាព គឺភាពនៃសាមគ្គី ភាពឬសេចក្ដីព្រមព្រៀង, ភាពស្រុះគ្នា) ។

– **មច្ឆិតា** គឺ **អប្បិច្ឆតា** ឬ **អប្បិច្ឆភាព**

(មច្ឆិតា ប្រែថា សេចក្ដីលោភលន់; ឯ-អប្បិច្ឆតា ប្រែថា ភាពឬបែបបទនៃអ្នកដែលមានសេចក្ដីប្រាថ្នាតិច ។ ឧទាហរណ៍ : ចិញ្ចឹមជីវិតដោយអប្បិច្ឆភាព) ។

**– អរិយធម៌ គឺ អនារ្យធម៌**

(អរិយធម៌ ឬ អារ្យធម៌ គឺធម៌ដែលនាំឲ្យកើតសេចក្ដីសុខចំរើន ។ល។ អនារ្យធម៌ ឬ អនាយ៌ធម៌ គឺធម៌ដែលនាំមកនូវទុក្ខសោក សេចក្ដីវិនាស )

**– ភុជិស្សភាព គឺ ទាសភាព**

(ភុជិស្សភាព ប្រែថា ភាពជាអ្នកជា ។ល។ ទាសភាព ប្រែថា ភាពនៃមនុស្សដែលជាខ្ញុំកំដរ ជាបាវព្រាវគេ ។ ឧទាហរណ៍ មនុស្សខ្សត់ទ្រព្យសម្បត្តិ ឬ ខ្សត់ប្រាជ្ញា ច្រើនតែធ្លាក់ក្នុងទាសភាព ) ។

x

x x

**ទី ១៧ – មនោសញ្ចេតនាចំពោះ**
**«អតីតសម័យនៃមាតុភូមិ»**

នៅក្នុងព្រៃដែលដុះព័ទ្ធបុរាណប្រាសាទនានា មានរបស់

ពីរយ៉ាង ដែលនាំបង្កើតដួងចិត្តទេសចរឲ្យរឹតតែស្រងេះស្រ-ងោចខ្លោចផ្សា ដោយសេចក្តីស្តាយអាល័យដល់កេរ្តិ៍ស្នាដៃនៃបុព្វបុរសខ្មែរ ។ វត្ថុនោះហាក់ដូចជាខ្យល់ព្រលឹងនិងសម្លេងនៃប្រវត្តិមាតុភូមិយើង ។

. . វេលាដែលព្រះសុរិយា កំពុងផុតបំហុយអស់ទាំងធម្មជាតិ រៃកណ្ដឹងយំទម្លាក់សំឡេងពីចុងស្រឡៅ ឬ ចុងឈើទាលដែលលូតលាស់ខ្ពស់ត្រដែតព្វង់វែហាស់ ។ ស័ត្វស្វរត្បូតទ្រើបមែកនេះជ្រោបចូលសព្វសព៌ាង្គកាយ ហើយមករំក្រសោបបេះដូងនាំឲ្យអ្នកដំណើរទាំងពួងយទចិត្ត អាសូរដល់ស្រុកកំណើតដែលធ្លាប់បានចុំចើង ។

នៅខែចេត្រនិងខែពិសាខ តាមផ្លូវពីក្រុងសៀមរាបទៅអង្គរ ផ្ការំដួលបញ្ចេញក្លិនរំភើយពិដោរក្រអូបឈ្ងុយឈ្ងប់ ។ បើជួនជាមានវាយោបក់បន្តិច ៗ ផង អ្នកដែលដើរយកអាកាសពេលល្ងាចតាមផ្លូវនេះ នឹងមានចិត្តរសាប់រសាយអណ្តែតអណ្តូង ប្រហែលជានឹងលាន់មាត់ថា ទោះជាស្ថានតុសិត

ក៏មិនសប្បាយជាជាងនេះទេមើលទៅ ។

ឱក្លិនរំដួល! ឱសំឡេងរៃ! កម្លាំងអ្នកដូចជាទិព្វឱសថ ដែលអាចចូលមករំលាយសេចក្ដីសោកសង្រេង មួយពេលបាន ។

នៅពេលរសៀល រទេះសេះមួយបរចូលតាមក្លោងទ្វារ មកក្នុងកំពែងនគរធំ ៗ ត្រចៀកប្រុងស្ដាប់ ភ្នែកប្រុងមើល នាងវិតាវីអង្គុយអែបនឹងមាតា ដែលនិយាយចេកចាចនឹងនាងសុចិត្រា គ្មានឈប់មាត់ឡើយ ។ នាងស្រីក្រមុំគិតតែក្នុងចិត្តថា: "ឱ ពីបុរាណកាល ម៉្លេះសមមានមនុស្សអ៊ូអរ កុះករមីរដេរ ដាស់អនេកអន័ន្ត" ។

ម្ដេចឡើយឥឡូវក៏វិលទៅជាព្រៃអស់រលីង មុខគួរឱ្យស្រណោះពេក ។

ឆ្ងួ - ហាច

ផ្កាស្រពោន

## សំណួរ

១- ចូរពន្យល់ពាក្យ ទេសចរ, ប្រវត្តិមាតុភូមិ, សព៌ាង្គកាយ, ពិដោរ, ទិព្វឱសថ, អនេក-អន័គ្ឃ ។

២- ក) ពាក្យ “ប្រព្រឹត្ត” សរសេរបានប៉ុន្មានបែប គឺអ្វីខ្លះ ?

ខ) ពាក្យ “អនុវត្ត” សរសេរបានប៉ុន្មានយ៉ាងដែរ ? គឺអ្វីខ្លះ ?

៣- តាមវេយ្យាករណ៍ខ្មែរ ការកនាមនិងករណនាមប្លែកគ្នាយ៉ាងណា ? ចូររកឧទាហរណ៍ក្នុងអត្ថបទខាងលើមកបញ្ជាក់ឲ្យបានមួយៗ ។

៣- ចូរធ្វើសម្ពន្ធប្រយោគ “វេលាដែលព្រះសុរិយាកំពុងដុត . . . ព្នង់រហាស់” ។

មធ្យមសិក្សាប័ត្រ

លើកទី២ ថ្ងៃ ៤-៨-៦៦

## កំណត់ចំណាំ

### ១. ពន្យល់ពាក្យ

- **ទេសចរ** ជនអ្នកធ្វើដំណើរលំហែកំសាន្ត ។ (កុំច្រឡំនឹង ទេសចរណ៍ គឺការធ្វើដំណើរកំសាន្តលំហែចិត្តនៃជនបរទេស ឬក៏ជាឈ្មោះក្រសួងរដ្ឋមន្ត្រីកាន់កាប់ខាងមុខការនេះ គឺក្រសួងទេសចរណ៍) ។
- **ប្រវត្តិមាតុភូមិ** ដំណើររឿងរ៉ាវ ឬសាវតារនៃមាតុភូមិ គឺរឿងរ៉ាវនៃភូមិកំណើត ទីកន្លែងទឹកដីដែលយើងកើត ។
- **សព៌ាង្គកាយ** (អាចសរសេរ សព្វាង្គកាយ) គ្រប់រូបរាងកាយទាំងមូល ។
- **ពិដោរ** ដែលមានក្លិនក្រអូបល្អ ដែលក្រអូបសាយ (ក្លិនពិដោរ, ផ្កាពិដោរ) ។

- ធិពួឱសថ ថ្នាំទិព្វ ។
- អនេកអនន្ត ដែលច្រើនកាត់ថ្លៃពុំបាន ។

២- អក្ខរាវិរុទ្ធ

- ទេសចរ (សរសេរ រ ចុង) ។
- រីត (សរសេរ រ ស្រៈ ី និង ត) ។
- ផ្សារ (សរសេរគ្មាន រ ចុងទេ) ។
- អាល័យ (សរសេរ ល័ និង យ) ។
- ធម្លាក់ (សរសេរគម្រូត ព្រោះមកពី ធ្លាក់) ។
- ធាល (សរសេរ ធា និង ល) ។
- សព៌ាង្គកាយ (អាចសរសេរជា សារពាង្គកាយ បាន) ។
- រុំ (សរសេរ ស្រៈ ុំ) ។
- ចេញត្រ (អានថា ចៃត្រ ។ សរសេរ ចៃ និង ត្រ) ។
- ពិសាខ (សរសេរ ពិ - សា និង ខ) ។
- ភ្លិន (សរសេរ ភ្លិ និង ន) ។

- ពិដោរ (សរសេរ រ ចុង) ។
- ស្ថាន (អាចសរសេរ ឋាន ដូច្នេះបាន) ។
- តុសិត (មានថា ជុះ - សិត ។ សរសេរ តុ - សិត ។ សិ និង ត) ។
- អ៊ូអរ (អរ មាន រ ចុង) ។
- កុះករមីរដេរដាស់ (ករ, មីរ, ដេរ សរសេរ មាន រ ចុង) ។
- អនេកអន័គ្ឃ (អង់គ្ឃ សរសេរ ង់ និង គ្ឃ) ។

៣- សទិសស័ព្ទ នៃពាក្យ .

១- ផ្សារ :

- ផ្សារ ជានាម គឺទីប្រជុំលក់ទិញរបស់ផ្សេងៗ (ផ្សារ ផ្សា) ។
- ផ្សា ជាកិ. ឬ គុ. ប្រែថា ឈឺចាប់ កើតពេល ពលផៀបៗ ដោយមុខស្រួច, របួស, ដាច់, រលាត់, ប៉ះពាល់ត្រូវ ប្រទះនឹងជាតិជូរប្រហើរ

(ខ្ចាបផ្កា) ។

- **ជ្រា** ជាអា.និ. ប្រែថា ព្រោះ, ហេតុតែ, ដោយហេតុ, តាមតែ (ផ្កាទឹងបាន គឺចង់តែទឹងបាន)។

**ជ្រា** ជាកិ. ប្រែថា ផ្សំតាមកម្ម, ផ្សំព្រេង, ត្រាំត្រូវ, ត្រាំអត់ (ផ្កាជាអ្នកកម្សត់) ។

- **ជ្រាវ** ជាកិ. គឺភ្ជាប់ក្លិតដោយទឹកបន្សារ (ផ្ការន្ធាំង) ។

២ - រំ :

- **រុំ** ជាកិ. គឺក្រសោបព័ទ្ធជិតជុំវិញ, បង់ព័ទ្ធ, មូរព័ទ្ធ (រុំខ្សែ, រុំរបួស) ។

- **រំ** ជាកិ. ប្រែថា ទទូរគ្របខ្លួនបង្ហប់កំស្ដួលចំហាយផ្សែង ៗ ដែលស្ងោរថ្នាំ ឲ្យក្ដៅចេញញើសពីសព៌ាង្គកាយ ដើម្បីឲ្យស្រាលខ្លួន, ធូរ (រំឲ្យជាភេគបុសដូនវិល) ។

- **រម** ជាគុ. ឬ នាម គឺដែលដុះក្រោយបន្ទាប់អែប

នៃបទនឹងគេ (ខ្នែងរម គឺខ្នែងតូចដែលដុះក្រោយ ហើយអែបនៃបទនឹងខ្នែងធំ ។ ផ្ការម គឺផ្កាត្នោតជាដើមដែលដុះលេចក្រោយ ដូចជាស្នៀតផ្កាប់ទឹងផ្កាធំ ហៅថា ក្លួររម ក៏បាន ។ ឈើគគីនេះមានដុះរម ច្រើនណាស់) ។

**ចំណាំ .–**

ពាក្យដែលមាន :

**១- រមពីមុខ** : រមណី, រមណីយ, រមណីយដ្ឋាន, រមណីយប្បទេស, រមណីយវ័ន, រមណីយារាម, រមណីយោទ្យាន, រមទម ឬ រម្យទម ។

**២- រម ពីក្រោយ**: អភិរម ឬ អភិរម្យ, មនោរម ឬ មនោរម្យ ។

**៣- រុំ ពីមុខ**: រុំកោះ (ដែលស្រមកច្រើនជាន់ ច្រើនស្រទាប់ ។ ក្អលរុំកោះ, ស្បូវគ្រងដំពាក់រុំកោះ ដំពាក់បំណុលគេរុំកោះ) ។

៤- រំ ពីមុខ រំកាប់, រំកាប់មាស, រំកាប់កោច,
រំកិល, រំខាន, រំគងកៃរស្នេហ៍, រំគាយ, រំគាល
រំគេញ, រំងក ឬ រម្ងក, រំងាច ឬ រម្ងាច, រំងាប់
ឬ រម្ងាប់, រំងាស់ ឬ រម្ងាស់, រំងើក ឬ រម្ងើក,
រំញាក, រំចីដៃ, រំបេក, រំដា, រំដីក, រំដីរដា,
រំដួល, រំដើប, រំដេញ, រំដៃ, រំដែក, រំដំរំដែង
រំដាក, រំដួល, រំដេក, រំដេង, រំដេញ, រំដេញ
មាស, រំដោះ, រំទំ ឬ រមទម, រំបល់, រំប៊ុក,
រំពង់, រំពត់, រំពា, រំពាត់, រំពាស់, រំពឹង,
រំពើក, រំពើន, រំពេ, រំពេច, រំពេន, រំពៃ,
រំកាយ, រំកើក, រំកើប, រំកើយ, រំយាក,
រំយីក, រំយោល, រំលង, រំលត់, រំលប់,
រំលស់, រំលា, រំលាក, រំលាង, រំលាយ,
រំលិច, រំលីង, រំលឹក, រំលុង, រំលុប, រំលុះ,
រំលូត, រំលើក, រំលើង, រំលៀក, រំលៀង,

រំលេច, រំលេប, រំលេម, រំលេះឬរំលែះ, រំលែក, រំលោភ, រំលោង, រំលោក, រំលំ, រំសាយ, រំសុស, រំសៅ, រំសោះ, រំហ, រំហ័ស, រំហាច, រំហុក, រំហូត, រំហួត, រំហើយ, រំហែ, រំហោក, រំអា, រំអិល ឬ រំឥល, រំអុក រំអួយ, រំអើក, រំអែង, រំអែរំអួយ, រំញុក ។

៣- បែត .-

- **ចែត** ជានាម គឺឈ្មោះកាំបិតផ្លែធំវែង ដងខ្លី (កាំបិតចែត) ។

- **ចេត្រ** ជានាម គឺឈ្មោះខែទី ៥ ខាងចន្ទគតិ (ខែចេត្រ) ។

៤- រាប .-

- **រាប** ជាគុ. គឺដែលមិនរដិបរដុប, ដែលឥតប៉ោង, ឥតខ្ពស់ទាប (ដីរាប, ផ្ទៃរាប, ឫកពាររាបទាប, សៀមរាប) ។

- **រៀប** ជាកិ. គឺធ្វើឲ្យមានរបៀប (រៀបផ្ទះ, រៀប-ស្រុក); តែង, ប្រដាប់ (រៀបខ្លួន), ចាត់ការធ្វើអាពាហ៍ពិពាហ៍ឲ្យតាមរបៀប (រៀបកូនឲ្យមានផ្ទះសម្បែង) ។
- **រៀបនឹង** ឬ **រៀប** ជាកិ. គឺទៀប, ហៀប, ជិតរកកល់ (រៀបស្លាប់, រៀបនឹងទៅ) ។

**ចំណាំ.-**

ពាក្យមានរៀបមុខ : រៀបចំ, រៀបរប, រៀបកប់ រៀបរាយ, រៀបរៀង ។

x

x x

## ទី១៨– រុក្ខទិវា

នៅឱកាសដែលសម្តេចទ្រង់បញ្ជាឲ្យរាជរដ្ឋាភិបាលប្រារព្ធរៀបចំពិធីរុក្ខទិវានេះឡើង មានប្រជាពលរដ្ឋខ្លះចេះតែនឹកឆ្ងល់ក្នុងចិត្ត ហើយចង់ដឹងនូវប្រយោជន៍ ព្រោះអ្នកទាំងនោះមិន

ដែលប្រទះព្រឹត្តិការណ៍នេះសោះ ៗ

តែប្រសិនបើយើងរិះគិតមើលទៅ យើងនឹងអស់សង្ស័យមិនបាន ដ្បិតពិធីរបៀបនេះជាទំនៀមទម្លាប់ខ្មែរតាំងពីបុរាណកាលរៀងដកបមក ដូចជាបុណ្យដាំដើមពោធិព្រឹក្សដែលមានគោលបំណងផ្សាយដំនឿខាងព្រះពុទ្ធសាសនា ហើយនិងផ្តល់ឥដ្ឋមនុញ្ញផលដល់ពុទ្ធសាសនិកជនដែលមានបសាទសទ្ធាជ្រះថ្លា ចូលរួមក្នុងបុញ្ញកម្មនេះ ៗ

រីឯរុក្ខទិភវិញ ចង់ញាំងពលរដ្ឋឲ្យស្គាល់យ៉ាងប្រត្យក្សនូវអត្ថប្រយោជន៍នៃឈើក្នុងបច្ចុប្បន្នជាតិ ៗ ឈើបំរើមនុស្សសព្វស្ពាលណាស់ តាំងពីយើងចាកឧទររបស់មាតារហូតដល់រំលាយខន្ធទៅវិញ ៗ យើងតែងយកឈើមកធ្វើជាឧស លំនៅឋាននិងឧបករណ៍ផ្សេងៗ ៗ ម្យ៉ាងទៀត ព្រៃឈើមានមុខងារជាអាថ៌កំបាំងខាងធ្វើឲ្យភ្លៀងធ្លាក់ និងទប់គង្គាកុំឲ្យជោរជន់លិចភូមិឋាន ដែលសាមញ្ញជនមិនងាយយល់ឡើយ ៗ ម៉្លោះហើយអ្នកបច្ចេកទេសតែងខំឆ្លៀតយកថ្ងៃដាំកូនឈើម្តងៗដើម្បី

ធ្វើជាវាគ្មិន ពន្យល់អ្នកផងឲ្យលុះក្នុងវិទ្យាសាស្ត្ររបស់ខ្លួន ។ ក្រៅអំពីនេះ ព្រៃឈើជារមណីយដ្ឋាន អាចទាក់ចិត្តនិងបំពេញអារម្មណ៍ទេសចរទាំងឡាយ ឲ្យស្បើយល្ហើយទុក្ខ បានសុខក្សេមក្សាន្ត ។

ទោះបីមានគោលដៅប្លែកគ្នាក្តី ក៏វនវប្បកម្មតាមប្រពៃណី ឬតាមសម័យនិយមសុទ្ធតែមានសារៈសំខាន់ដូចគ្នា សមនឹងសុភាសិតឥណ្ឌាមួយថា "អ្នកណាបានដាំឈើមួយដើមមុននឹងស្លាប់ទៅ មិនមែនបានរស់នៅឥតប្រយោជន៍ឡើយ" ។

## សំនួរ

១– **ន័យនៃពាក្យ** រុក្ខទិវ, ប្រារព្ធ, ឥដ្ឋមនុញ្ញផល, បុញ្ញកម្ម, វាគ្មិន, វនវប្បកម្ម ។

២- **ចូររកសព្ទញាតិ** នឹងពាក្យ "ប្រជា" ដោយឲ្យន័យនៃពាក្យនីមួយៗ ផង ។

៣- **សមាសនាម** និង **សមូហនាម** មានការប្លែកគ្នាយ៉ាងណា ? ចូរស្រង់ឧទាហរណ៍

ដែលមាននៅក្នុងឃ្លា "នៅឱកាសដែល
សម្ដេច .... ព្រឹត្តិការណ៍នេះនោះ" ដោយ
បញ្ជាក់ពាក្យនីមួយ ៗ ទៅតាមប្រភេទនៃ
នាមទាំងពីរយ៉ាងនេះ ។

៤- ឈើមានប្រយោជន៍ អ្វីខ្លះចំពោះមនុស្ស
ទៅ ?

មធ្យមសិក្សាបត្រ
លើកទី ១ ថ្ងៃ ១៩-៦- ៧

## កំណត់បំណាំ

### ១- ពន្យល់ពាក្យ -

- វុក្ខទិវា ថ្ងៃបុណ្យប្រារព្ធធ្វើពិធីដាំដើមឈើជា និមិត្តរូបនៃការរក្សាគ្រង បង្កើនព្រៃឈើ ។
- ប្រារព្ធ តាំងផ្ដើម, ផ្ដួចផ្ដើម, ប្រុងប្រៀប, រៀប ចំ, នឹកដើម, គិតដល់, ភ្ញាក់នឹកដល់ ។
- ឥដ្ឋមនុញ្ញផល ផលជាទីពេញចិត្តដែលបាន

សម្រេចដូចបំណង ។

- **វាគ្មិន** អ្នកឈ្លាសសំដី, អ្នកមានសំដីថ្មីមាត់ (l'orateur) ។

- **វនវប្បកម្ម** ការបណ្ដុះបណ្ដាល បង្កើតបង្កើន ខាងព្រៃឈើ ។

**២- សព្ទញាតិ** នៃពាក្យ **ប្រជា** :

- **ប្រជា** គឺពពួកសត្វ, ពពួកជន (ប្រជាករ) ។
- **ប្រជាករ** ឬ **ប្រជាជន** គឺពួកជនចំណុះប្រទេស (le peuple) ។
- **ប្រជាជាតិ** គឺជាតិនៃមនុស្សដែលមានវង្សត្រកូល និងភាសាជាមួយគ្នា (la nation) ។
- **ប្រជាធិបតី** គឺអធិបតីរបស់ប្រជា (ព្រះរាជា) ។
- **ប្រជាធិបតេយ្យ** គឺភាពនៃប្រទេសដែលមាន ប្រជារាស្ត្រជាអធិបតី គឺប្រទេសឬរដ្ឋបាល ដែលមានប្រជាជនជាធំ ក្នុងការរើសតំណាង

របស់ខ្លួន ឲ្យជាអ្នកសម្រេចកិច្ចការក្នុងប្រទេស (la démocratie) ។

– **ប្រជានិករ** គឺពួកប្រជារាស្ត្រ, ពួកមនុស្ស (la population) ។

– **ប្រជាពលរដ្ឋ** គឺពលរដ្ឋប្រជាជន (le peuple) ។

– **ប្រជាភិថុតិ** គឺការបញ្ជោរ ឬការបញ្ចើចលើកជើងប្រជារាស្ត្រ (la démagogie) ។

– **ប្រជាភិបាល** គឺអ្នកគ្រប់គ្រងប្រជាជន (ព្រះរាជា) le gouvernant, le gouvernement

– **ប្រជាភិវឌ្ឍ** គឺការលូតលាស់ដុះដាលរបស់ប្រជារាស្ត្រ, ការបណ្ដុះបណ្ដាលមនុស្ស សត្វ គ្រឿងតំបន់ដែលមិនធ្លាប់មានក្នុងកាលមុន ឲ្យកើតមានឡើង ឲ្យបានរីកចម្រើនឡើងជាលំដាប់ ។

– **ប្រជាមតិ** គឺមតិ ឬយោបល់ប្រជារាស្ត្រ (le référendum) ។

- ប្រជាមានិត ដែលប្រជាជនចូលចិត្តស្រឡាញ់ រាប់អាន, ដែលទាក់ទងដល់ប្រជារាស្ត្រ, ដែលមានផលប្រយោជន៍ដល់បណ្ដាជនទូទៅ (populaire) ។
- ប្រជារាស្ត្រ ឬ រាស្ត្រប្រជា គឺពួកជនចំណុះដែន (le peuple, la population) ។
- ប្រជាប្រិយ គឺដែលប្រជារាស្ត្រនិយម ស្គាល់ ចូលចិត្ត (populaire) ។
- ប្រជាប្រិយភាព គឺការៈដែលប្រជារាស្ត្រពេញចិត្ត ទទួលស្គាល់ ស្រឡាញ់ ទំនុកទុកចិត្ត (la popularité) ។ល។

៣. អក្ខរាវិរុទ្ធ.–

- ប្រារព្ធ (សរសេរ ប្រា–រ និង ព្ធ) ។
- ជីរាប (ជិ គ្មានអស្ដាទេ) ។
- ពុទ្ធសាសនិក (និក សរសេរ និ និង ក) ។

– **ស្និទ្ធស្នាល** (ស្និទ្ធ សរសេរ ស្និ និង ទ្ធ) ។

– **ឧទរ** (ទរ មាន រ ចុង) ។

– **ឧស** (អាចសរសេរ អុស ដូច្នេះបាន) ។

– **ឋាន** (អាចសរសេរ ស្ថាន បាន) ។

– **ឧបករណ៍** (ករណ៍ សរសេរ ក – រ និង ណ៍) ។

– **គង្គា** (គ្មាន រ ចុងទេ) ។

– **ទ្វារ** (មាន រ ចុង) ។

– **តណ្ហា** (សរសេរនឹងស្រៈ –ា) ។

៤- **សទិសសព្ទ** នៃពាក្យ :

១- **កាល** :

– **កាល** ជានាម ប្រែថា គ្រា, ពេល, សម័យ, (កាលនោះ, កាលបរិច្ឆេទ) ។

– **កាល** ជានាម ប្រែថា មច្ចុរាជ, សេចក្ដីស្លាប់ (ព្រះកាលតែងផ្ដាច់ផ្ដិលនូវអាយុសង្ខារនៃសត្វលោក) ។

- **កាឡ្ស** (កាឡកណ្ណី) ជានាម គឺមនុស្សឥតបុណ្យ, មនុស្សចង្រៃ (ដូចគ្នានឹងពាក្យ កាឡកិណី ប្រែថា មនុស្សធ្វើនូវនិស្ស័យនៃខ្លួនឲ្យប្រាកដស្មើដោយវត្ថុមានពណ៌ខ្មៅ (មនុស្សកាឡកិណី, ស្រីកាឡកិណី) ។
- **កល្ប** ជានាម ប្រែថា កាលដែលតាំងនៅយូរអង្វែង (មួយកប្បមួយកល្ប, កើតនេះកល្ប ឬកើតប្រល័យកប្ប) ។

២- ព្រឹក្ស :

- **ព្រឹក្ស** ជានាម ប្រែថា ឈើ (ខ្មែរច្រើនប្រើពាក្យនេះផ្សំជាបទសមាស រៀងខាងចុងនៃនាមសព្ទដែលជាឈ្មោះឈើផ្សេងៗ (ដូចជា : កល្បព្រឹក្ស, ជម្ពូព្រឹក្ស, និគ្រោធព្រឹក្ស, ពោធិព្រឹក្ស)។
- **ព្រឹក** ជានាម គឺវេលាចាប់តាំងពីព្រះអាទិត្យបំព្រាងដល់ថ្ងៃពេញពន្លឺធំ (ព្រឹកល្ងាច, ព្រឹកព្រាង) ។

៣- ឧស :

- **ឧស ឬ អុស** ជានាម គឺឈើសម្រាប់ដុត (រក ឧស, បាច់អុស, គំនរអុស) ។

- **អូស** ជាកិ. ប្រែថា ទាញរំកិលជិតជាប់លើដី ឬ លើផ្ទៃទឹក (អូសទូកចុះទឹក, អូសសម្រាស់) ។

៤- សា :

- **សា** ជាកិ. ប្រែថា មូរឡើងវិញ (សាកន្ទេល); កើបឡើងវិញ (សាស្រូវ); -ត្រឡប់វិញ (សាមកវិញ, ដើរសាចុះ សាឡើង); - រើឈឺឡើងវិញ (សាឈឺឡើងវិញ); - និយាយថ្លែងពីទុក្ខ (និយាយសាទុក្ខ); - និយាយជាថ្មីទៀត (សានិយាយម្ដងទៀត) ។

- **សា** ជានាម គឺដំណើរត្រឡប់ទៅមក ឬចុះឡើង, ដង, គ្រា, ត្រឡប់, ចក (ដើរមួយសាពីរសា)។